# LE CALICE JUSQU'A LA LIE

# រងចុកចាប់រហូតដល់អាចសាន

## ដោយ នរោត្តម-សីហនុ

បកប្រែក្រៅផ្លូវការដោយ

## សុទ្ធ~ប៉ូលិន

ការផ្សាយរបស់ អង្គរបុរី
គ.ស.២០០៤ ★ ព.ស.២៥៤៨

# វគ្គទី១ ជំពូក១០

## និច-សុនជួយសង្គ្រោះលន់-នល់, ការបោកបញ្ឆោតនៃ កម្មវិធីរបស់ពួកខ្មែរក្រហម, ម៉ៅគាំទ្រពួកហ្វ៊ុង...

ខែឧសភាឆ្នាំ១៩៧០ ជាខែមួយដែលពោរពេញដោយព្រឹត្តិការណ៍ ។ ខែនេះបានចាប់ផ្តើមឡើង ដោយមានរន្ធះបាញ់ទាំងកណ្តាលថ្ងៃត្រង់ ដែលបណ្តាលឲ្យផ្អើលចលាចលរីករវររញ្ជួយដល់ពិភពលោកទាំងមូល... មិនត្រឹមតែប៉ុណ្ណោះ ដែលបណ្តាលឲ្យមានការបែកបាក់គ្នានៅក្នុងមតិសាធារណជនរបស់ជាតិ(ខ្មែរ)ផង ព្រមទាំងនៅសហរដ្ឋអាមេរិកផង, គឺជាការបែករហែកឃ្លាតចាកគ្នា ខាងផ្លូវសីលធម៌ ខាងផ្លូវចិត្ត ដែលចេះតែមានសភាពធ្ងន់ធ្ងរឡើងៗជារឿងដរាបរហូតទៅនៅក្នុងខែ និងឆ្នាំតទៅមុខ ។

នៅក្នុងឆ្នាំ១៩៧៩ នៅទីក្រុងប៉េកាំង លោកហេនរី-គីស្ស៊ីងគ្ញើរ ហើយនិងខ្ញុំព្រះករុណាខ្ញុំ ដែលទាំងពីរនាក់បានក្លាយទៅជា «ជនចូលនិវត្តន៍» នៅក្នុងបញ្ហាន-យោបាយរបស់រដ្ឋ, យើងបានជួបគ្នាជាលើកដំបូងបំផុត ដោយសារតែមានការរៀបចំ របស់មិត្តរួមរបស់យើង គឺសាធារណរដ្ឋប្រជាមានិតចិន ។ ខ្ញុំបានរំលឹកចំពោះភ្ញៀវអាមេរិកាំងរបស់ខ្ញុំ អំពីសភាពការណ៍រន្ធះបាញ់កណ្តាលខែចេត្រ ដែលបានផ្ទុះឡើងនៅខែឧសភា១៩៧០ របស់ប្រធានាធិបតីនិច-សុន (ដែលគីស្ស៊ីងគ្ញើរ ជាខួរក្បាលមួយដ៏សំខាន់បំផុត), អំពីអន្តរាគមន៍យោធាអាមេរិកាំងទៅជួយខាងលន់ នល់ និង«ក្រុមបន»របស់វាក្នុងប្រការកុំឲ្យពួកនេះដួលរលំបះជើង... ព្រោះថាបើក្រុមពួកនេះដួលរលំទៅខ្ញុំព្រះករុណា ខ្ញុំ នឹងមានលទ្ធភាពអាចវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ដើម្បីជួយស្តារសភាពការណ៍ មួយប្រកបដោយគ្រោះថ្នាក់ដល់ស្លាប់ មិនត្រឹមតែទាក់ទងប្រទេសយើងមួយប៉ុណ្ណោះទេ ប៉ុន្តែទាក់ទងនឹងជំហររបស់អាមេរិកាំងនៅក្នុងភពឥណ្ឌូចិនទាំងមូលទៀតផង, ដោយហេតុថាកាលនោះ ពួកខ្មែរក្រហមមានតិចតួចណាស់ ចំណែកពួកចិននិងពួកវៀតណាមខាងជើង ក៏មានគោលបំណងក្នុងវេលានោះ ឲ្យប្រទេសកម្ពុជាវិលត្រឡប់ទៅសភាពការណ៍ដដែលដូចដើមវិញដែរ «statu-quo ante» ។

លោកគិស្ស៊ីងគ្ញើរពេលនោះ ក៏បានថ្លែងប្រាប់ខ្ញុំព្រះករុណា ខ្ញុំថាខ្លួនលោកក៏ចង់ឲ្យលន់-នល់ធ្លាក់ និងឲ្យមានការវិលត្រឡប់របស់សម្តេចសីហនុវិញដែរ, ក៏ប៉ុន្តែ

លោកបានយល់ថា ពួកក្រុមក្បត់ហើយនិងខ្ញុំព្រះករុណា ខ្ញុំកំពុងតែលេងល្បែងចូលគ្នា... ដោយបង្កើតរដ្ឋប្រហារក្លែងក្លាយមួយ «ទម្លាក់ស្តេច» ដើម្បីបោកបញ្ឆោតយៀកកុងនិងយៀកណាមខាងជើង ។ ខ្ញុំបានឆ្លើយសារភាពពេលនោះទៅភ្ញៀវអាមេរិកាំងថា ប្រាជ្ញាដ៏ខ្ពីរបស់ខ្ញុំព្រះករុណា ខ្ញុំមិនអាចយល់បានអំពីទស្សនៈរបស់គាត់បែបនេះទេ ។

ទោះជាយ៉ាងណាក្តី, គេអាចយល់បានថា ប្រសិនបើលោកប្រធានាធិបតីនិច-សុន អាចធ្វើការទស្សន៍ទាយឬសម្លឹងមើលឃើញអនាគតបាន, ដូចម៉ាដាម Soleil ឬក៏លោក Jean Viaud, លោកច្បាស់ជាចៀសវាងមិនប្រថុយប្រថានលោតចូលទៅក្នុងសភាពការណ៍ជួយសង្គ្រោះមួយ ដែលបានក្លាយ២-៣ឆ្នាំក្រោយមកទៅជា «អត្តឃាតកម្មនយោបាយ» មិនត្រឹមតែប៉ុណ្ណោះត្រូវប្រទ្បាក់ប្រទ្បូស ដោយសភាពអាម៉ាស់ថោកទាប នៅចំពោះមុខជាតិរបស់ខ្លួនឯង ។

គេមិនអាចសរសេរប្រវត្តិសាស្ត្រឡើងវិញបានទេ ។ ក្នុងប្រការនេះ គេអាចត្រឹមតែយកមកធ្វើការសិក្សាតែប៉ុណ្ណោះ, យ៉ាងហោចណាស់ក៏អាចមើលឃើញជ្រុងជ្រោយខ្លះៗដ៏សំខាន់ៗ ។ ម្ល៉ោះហើយ វិភាគព្រឹត្តិការណ៍ដ៏ល្អប្រសើរបំផុតចំពោះខ្ញុំព្រះករុណា ខ្ញុំ, នៃខែឧសភាឆ្នាំ១៩៧០នោះ លេចឡើងក្នុងអត្ថបទមួយដ៏ត្រចះត្រចង់ប្រកបដោយការពិត និងដោយវិចារណញ្ញាណ, របស់លោក Jacques Doyon (ដែលខ្ញុំព្រះករុណា ខ្ញុំ មិនបានស្គាល់ដោយផ្ទាល់ខ្លួននោះទេ) គឺអត្ថបទមួយចុះផ្សាយក្នុងកាសែត Le Figaro, នៃថ្ងៃទី២៦ ឧសភាឆ្នាំ១៩៧០, ហើយដែលខ្ញុំព្រះករុណា ខ្ញុំសូមដកស្រង់ឃ្លាខ្លះៗដូចតទៅនេះ ។ «ពួកអ្នកតំណាងរាស្ត្រខ្មែរ ដែលបានកាត់ក្បាលសីហនុ, នៅថ្ងៃ១៨មិនាឆ្នាំ១៩៧០, ស៊ឹម-វ៉ារ, ឌុក-រ៉ាស៊ី, ទ្រិញ-វ៉ាញ... ពួកអ្នកដែលបានណែនាំឲ្យមានការបោះឆ្នោតទម្លាក់ជាឯកច្ឆន្ទ, តើពួកនេះមានបានថ្លឹងថ្លែងអំពីកាយវិការរបស់ខ្លួនឬទេ ? ពីរខែក្រោយមកទើបគេអាចសម្លឹងមើលឃើញសភាពធ្ងន់ធ្ងរនៃមហាអន្តរាយ...(...) ។ បញ្ហាសោកនាដកម្មគឺវាបណ្តាលមកអំពីអសមត្ថភាពនៃអ្នកដឹកនាំខ្មែរ ដើម្បីយល់អំពីសភាពការណ៍យៀកកុង ។ សម្តេចសីហនុបានបង្ហាញដល់ពួកអ្នកទាំងនេះហើយតាងនាមនយោបាយរេចុះឡើងរបស់ទ្រង់, ថាបញ្ហានេះវាគឺជាបញ្ហាមួយលំបាកណាស់ ។ ប្រការដែលសំខាន់សំរាប់សម្តេចសីហនុ គឺពួកយៀកកុងគេបានទទួលស្គាល់ជាផ្លូវការ នូវគំនូសព្រំដែននៃកម្ពុជា, ដែលពួកព្រៃនគរក្តី, បាងកកក្តី ហើយសូម្បីតែវៀងចន្ទក្តី, ម្នាក់ៗសុទ្ធសឹងតែបានទាមទារទឹកដីមួយចំណែកនៃព្រះរាជាណាចក្រកម្ពុជា (ខ្ញុំព្រះករុណា ខ្ញុំសូមគូសសំគាល់ដល់មិត្តអ្នកអាន ទាំងអស់ថាកាសែត Le Figaro គឺជាកាសែតខាងស្តាំ, ក្នុងប្រការនេះជាកាសែតដែលប្រឆាំង

កុម្មុយនិស្ត ហើយប្រឆាំងនឹងបដិវត្តន៍ ។ ម៉្លោះហើយការវិនិច្ឆ័យនៃសារពត៌មាននេះមានតម្លៃខ្លាំងណាស់- ន. សីហនុ) ។ ម៉្លោះហើយសម្តេចសីហនុ អាចទទួលឲ្យមានការតាំងទ័ពរបស់យៀកកុងនៅក្នុងដីខ្មែរដែលលោកយល់ថា ជាប្រការបណ្តោះអាសន្ន ដែលមានកំណត់រហូតដល់ការចប់សង្គ្រាមតែប៉ុណ្ណោះ (ជាការពិត, ខ្ញុំមិនយល់ព្រម ឲ្យមានទីតាំងយៀកកុងជារៀងរហូតនោះទេ ។ ន. ស.) ៖ ការយល់ព្រមនេះ គឺជាថ្លៃថ្នូរនៃសេចក្តីសុខសន្តិភាពនៅប្រទេសកម្ពុជា ។ ចំពោះរដ្ឋាភិបាលលន់នល់ ថ្លៃថ្នូរគឺជាសង្គ្រាមទៅវិញ ។ អន្តរាគមន៍អាមេរិកាំងមានផលវិបាកដ៏ជ្រាលជ្រៅក្រៃលែង ដែលគេមិនអាចស្មានបាន ។ វាមានទិដ្ឋិភាពមួយដែលអន្តរាគមន៍មានលក្ខណៈអសិលធម៌... មិនត្រឹមតែប៉ុណ្ណោះ ប្រការនេះបានជំរុញឲ្យកងទ័ពអាមេរិកាំងទាំងមូល ដែលស្វែងរកប្រសិទ្ធិភាពខាងផ្លូវយោធា ឲ្យប្រព្រិត្តនយោបាយនៃអគ្គីភ័យ ។ ការទម្លាក់គ្រាប់បែក, ការដើរគៀងប្រមូលប្រជាជន... គឺសុទ្ធសឹងតែជាអំពើដែលជំរុញឲ្យយុទ្ធជនដ៏ច្រើនរាប់ពាន់ម៉ឺននាក់ រត់តម្រង់ចូលជួរប្រយុទ្ធខាងស្តេចសីហនុ ។ យោងតាមប្រភពច្បាស់ការណ៍ គេអាចនិយាយបានថា កងទ័ពសីហនុត្រូវបានទទួលជាកងទ័ពរំដោះជាតិ ពីសំណាក់ប្រជាកសិករ, បន្ទាប់ពីមានការហិនហោច ដែលបណ្តាលឡើងពី កងទ័ពអាមេរិកាំង ។ ផលវិបាកដ៏សែនធ្ងន់ធ្ងរមួយទៀត...គឺអន្តរាគមន៍នេះ វាបានរៀបចំឲ្យមានទីតាំងដ៏សំបើមនៃកងទ័ពវៀតណាមខាងត្បូង ។ គេធ្វើហាក់ដូចជាកងទ័ពនេះជារបងចុងក្រោយរបស់លន់-នល់ ដើម្បីការពារតទល់នឹងយៀកកុង ដើម្បីកុំឲ្យដួលរលំខ្លួនឯង ( <u>កកន</u> ៖ ខ្ញុំនៅចាំច្បាស់ណាស់ថា នៅពេលដែលសារពត៌មានខ្មែរបានធ្វើការទិតៀនការលួចប្លន់របស់កងទ័ពវៀតណាមខាងត្បូងខាងលើនេះ លោកអ៊ិន-តាំដែលកាលនោះជាចៅហ្វាយខេត្តកំពង់ចាម បានគំរាមកំហែងពួកអ្នកកាសែតឲ្យបិទមាត់ដោយប្រការថា ៖ « ពួកវៀតណាមខាងត្បូងទាំងនេះគេមកជួយយើង...» សុទ្ធ-ប៉ូលិន) ។ យើងស្ថិតនៅចំពោះមុខសភាពការណ៍សម្ព័ន្ធបក្សមួយ រវាងកងទ័ពវៀតណាមព្រៃនគរនិងពួកខ្មែរដែលអ្នកទាំងពីរនេះគ្មានសេចក្តីស្នេហាចំពោះគ្នា សូម្បីតែបន្តិចបន្តួច.. តទល់នឹងពួកយៀកកុង ។ គឺជាសម្ព័ន្ធមេត្រីដ៏ប្រកបដោយ គ្រោះថ្នាក់បំផុតសំរាប់ប្រទេសកម្ពុជា ដោយនរណាៗក៏ដឹងដែរថា ក្រុងព្រៃនគរបានទាមទារជាផ្លូវការ តាំងពីឆ្នាំ១៩៦០មកម៉្លេះ នេះរាប់ត្រឹមតែកោះសមុទ្រខ្មែរស្ទើរតែទាំងអស់ ដែលនៅជាប់ក្បែរនឹងទីក្រុងកំពត ។ ចំណែកនៅខាងលិចវិញ ទីក្រុងបាងកកបានសន្យាថានឹងជួយគាំទ្រប្រទេសខ្មែរ ។ នេះគឺជា «មិត្តភាពក្បាលពីរមួយទៀត» បើយោងតាមសំដីរបស់ប្រជាកសិករខ្មែរ, ដោយហេតុថាបាងកកតាំងពីឆ្នាំ១៩៤១មកម៉្លេះ ដោយមានការគាំទ្រពីប្រទេសជប៉ុន បានវាតយកទឹកដីខ្មែរអស់១/៣ ហើយដែលបានយល់ព្រមត្រ-

ឡប់ទឹកដីនេះមកខ្មែរវិញ ទាំងទើសទាំងទាល់នៅក្នុងឆ្នាំ១៩៤៧ ។ បញ្ហាគំនូសព្រមដែននេះ គឺជាបញ្ហាស្លាប់រស់របស់ប្រទេសកម្ពុជា ហើយសម្ដេចសីហនុលោកបានដឹងច្បាស់ណាស់អំពីរឿងនេះ, លោកដែលបានជួបប្រទះនឹងការលំបាកក្រៃពេក ក្នុងប្រការរឹតចំណងចងបាច់សាមគ្គីភាពដ៏ស្ដួមមួយនៃជនជាតិខ្មែរ ដែលជា«ជនភាគតិច» ។ សាមគ្គីភាពដែលលោកបាន
បង្កើតនៅជុំវិញខ្លួនតទល់នឹងពួកឃុនគ្រប់និន្នាការ (កកន ៖ អ្នកនិពន្ធបានសរសេរ Viet / វៀត គឺយួនកុម្មុយនិស្ត) តទល់នឹងពួកថៃនិងពួកលាវថែមទៀត ។ ការយល់សប្តិស្រែកឃ្លានរបស់ពួកបាងកកនិងពួកព្រៃនគរ មិនគឺការចង់បានព្រំប្រទល់តែមួយជា «ប្រវត្តិសាស្ត្រ» នៅតាមដងទន្លេមេគង្គនោះទេឬ ? ការទទួលស្គាល់ព្រំប្រ-ទល់នៃកម្ពុជា គឺជាបញ្ហាស្លាប់រស់របស់សម្ដេចសីហនុ ព្រមទាំងជាដើមកំណើតនៃការផ្ដាច់ចំណងទូតដ៏ខ្ជូរខ្ជារជាច្រើន ។ ការប៉ិនប្រសប់នៅក្នុងនយោបាយរបស់ឧត្តមសេនិយ ដឺហ្គោល គឺជាការប្រកាសទទួលស្គាល់ កាលពីឆ្នាំ១៩៦៦ «គោរពបូរណភាពទឹកដីកម្ពុជា នៅក្នុងព្រំដែនបច្ចុប្បន្ន» (ពាក្យដែលមានគំនូសបន្ទាត់ពីក្រោមមានបោះពុម្ពផ្សាយនៅក្នុងកាសែត Le Figaro នៃថ្ងៃទី២៦ឧសភា១៩៧០, បោះពុម្ពជាអក្សរទ្រេត... ន. ស.) ។

«នៅក្នុងពេលបច្ចុប្បន្ននេះ យើងស្ថិតនៅលើជំរេច្រាំងនៃការពុះចែងចែកទឹកដីម្ដងទៀតហើយតទៅអនាគតដ៏ខ្លី, បើទោះជាខ្មែរមានទម្លាប់នៃការតស៊ូតទល់នឹងវាតត្បាតទឹកដីយ៉ាងណាក៏ដោយ ។ ផលវិបាកមួយទៀតរបស់រដ្ឋប្រហារលន់-នល់ ៖ ការរាលដាលនៃភ្លើងសង្គ្រាមទៅលើទឹកដីទាំងមូលនៃជ្រោយឥណ្ឌូចិន ។ ប្រទេសកម្ពុជាខ្លួនឯង ក៏ចាប់ផ្ដើមក្រឡេកមើលបន្តិចម្ដងៗ ឃើញថារូបខ្លួនកំពុងតែក្លា-យទៅជាចំណីភ្លើង (...) ។ នៅចុងបញ្ចប់ទៅទិសដៅនៃសង្គ្រាមឥណ្ឌូចិនត្រូវធ្វើដំណើរទៅតាមមាគ៌ាខាងស្ដាំ រវាងបាងកក-វៀងចន្ទ-ភ្នំពេញ-សៃហ្គង, ដែលយើងបាននិយាយរៀបរាប់កាលពីរខែកន្លងទៅ ។ គឺជាមាគ៌ាអសិលធម៌ ផ្ទុយនឹងធម្មជាតិមាគ៌ានៃពួកយោធានិយម ដែលស្អប់ខ្ពើមកុម្មុយនិស្តជាទីបំផុត សម្ព័ន្ធមេត្រីនៃពួកប្រយុទ្ធសង្គ្រាមសាសនា នៃសង្គមជំនាន់ដើមនៅអាស៊ីភាគអាគ្នេយ៍ ។ រូបារម្មណ៍នេះ, ទិដ្ឋភាពនយោបាយនឹងរៀបចំតទៅអនាគត នូវសេចក្ដីស្នេហារវាងប្រទេសសំខាន់ៗពីរ ដែលប្រួអាមេរិកាំងនៅអាស៊ីភាគអាគ្នេយ៍...សេចក្ដីស្នេហាព្រៃនគរ-បាងកកដ៏ស្ដុកស្ដម, តើនរណាអាចដឹងបាន, ដែលហូបទៅសំណល់នៃប្រទេសកម្ពុជានិងប្រទេសលាវ ។ ហើយតើគេមិនអាចមើលឃើញភ្លើងសង្គ្រាម១០ឆ្នាំតទៅមុខទៀតទេឬនៅពេលដែលអាមេរិកដកទ័ពខ្លួនមួយភាគធំចេញផុតពីភូមិភាគអាស៊ីភាគអាគ្នេយ៍, នៅចន្លោះប្រទេសវៀតណាម ដែលពេលនោះត្រូវរួបរួមគ្នាវិញ ហើយនិងប្រ

ទេសថៃ ?» ។

(ចាប់តាំងពីចន្លោះឆ្នាំ១៩៧៩ ប្រទេសថៃនឹងត្រូវប្រឈមមុខតទល់នឹងវៀតណាមដែលរួបរួមគ្នា ហើយការការពារខ្លួនរបស់ពួកនេះទល់នឹងពួកយួន គឺការយកទ័ពប៉ុល-ពតមកធ្វើជារបងសាច់ឈាមតែប៉ុណ្ណោះ... ន.ស.) ។

«យោងតាមសារពត៌មាន «Chicago Sun Times» លោកប្រធានា ធិបតីនិច-សុនបានថ្លែងទៅកាន់ថៅហ្វាយរដ្ឋអាមេរិកាំងទាំងអស់ ដែលមកប្រជុំគ្នានៅសេតវិមាន, ថាលោកបានបញ្ជូនកងទ័ពអាមេរិកាំង ទៅប្រទេសកម្ពុជា ទៅតាមសេចក្តីស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា (ខ្សែកាប AFP... Chicago... ចុះថ្ងៃ១៣ឧសភា១៩-៧០) ។ សេតវិមាន, យោងតាមសារពត៌មាន «Chicago Sun Times ដដែល... ធ្លាប់តែបានអះអាងយ៉ាងដាច់ខាតថា សហរដ្ឋអាមេរិកបានសំរេចធ្វើអន្តរាគមន៍ពីខ្លួនឯង ក្នុងគោលបំណងកុំឲ្យប្រទ្បាក់ប្រឡូសដល់អព្យាក្រឹត ភាពជាផ្លូវការនៃរដ្ឋាភិបាលលន់-នល់» ។

ដូច្នេះគេអាចឃើញច្បាស់ណាស់ថា, តាំងពីដំបូងទីមកម្ល៉េះ ពួករដ្ឋប្រហារនៅភ្នំពេញ ហើយនិងក្រុងវ៉ាស៊ិនតោនមានការត្រូវរ៉ូវគ្នា ដើម្បីបញ្ចប់អព្យាក្រឹតភាពហើយនិងសន្តិភាពនៅប្រទេសកម្ពុជា ។ ពួកគេមានការត្រូវរ៉ូវគ្នា ដោយរុញបញ្ចូលប្រទេសកម្ពុជាជាស្ពានទៅក្នុងសង្គ្រាមវៀតណាម ដើម្បីធានាជោគជ័យចំពោះអាមេរិកាំងនៅវៀតណាមខាងត្បូង និងចំពោះរបបរណបរបស់ង្វៀង-យ៉ាំងធីវ ។

ការវាតត្បាតប្រទេសកម្ពុជាដោយកងកម្លាំងទ័ពនៃសហរដ្ឋអាមេរិក-វៀតណាមខាងត្បូងនៅក្នុងខែឧសភា១៩៧០, ជាដើមហេតុមួយនៃការ បំផុសបំផុលដល់កំពូលទៅលើពួកបញ្ញវ័ន្ត ហើយនិងទៅលើក្រុមសារពត៌មាននៅភ្នំពេញ ។ គឺជារឿងមួយគួរឲ្យចង់សើច ព្រោះគេចាត់ទុកថា ការវាតត្បាតនេះ...ជាចំណាត់ការប្រវត្តិសាស្ត្រមួយដែលនឹងលើកដំកើងលោកប្រធានាធិបតីនិច-សុន ឲ្យមានលក្ខណៈសំបើមធំធេង ស្មើនឹងប្រធានាធិបតីមុនៗដ៏ធំៗជាងគេនៃសហរដ្ឋអាមេរិក, «ស្មើនឹងហ្ស៊ូជ-វ៉ាស៊ិនតោន ហើយនិងអាប្រាហាម-លិងកិន», មិនស្មើរទេ ! ស្របជាមួយគ្នាពួកបញ្ញាជនហើយនិងក្រុមអ្នកកាសែតដដែលដៀលត្មះប្រាស់ឆ្អេះដ៏សំបើមទៅលើស្រុកបារាំងថា ជាអ្នកកាន់ជើងសីហនុ, (Pro-Sihanouk-sic!) ។ល។ ព្រមទាំងទៅលើអ្នកយកការណ៍ពត៌មានបារាំង ។ នៅក្នុងប្រការនេះ, លោក Bernard Ullman (AFP) បានសរសេរផ្សាយនៅថ្ងៃទី៧ឧសភា (ខ្ញុំព្រះករុណា ខ្ញុំ សូមលើកយកអត្ថបទរបស់គាត់ផ្ញើមកពីភ្នំពេញមកផ្សាយទាំងស្រុង) ៖ «ថ្ងៃនេះ សារពត៌មានក្នុងស្រុកបានតម្លើងធ្មុងរបស់ខ្លួន ដើម្បីវាយប្រហារទៅលើគោលជំហរបារាំង ទាក់ទងនឹងបញ្ហាសង្គ្រាមស្រុកខ្មែរ ព្រមទាំងបានប្រកាសដោយត្រង់ឲ្យដេញអ្នកសារពត៌-

មានបារាំងឲ្យចេញពីទីនេះ ។ មានសាស្ត្រាចារ្យម្នាក់ ដែលបានរៀនសូត្រនៅប្រទេសបារាំងបានធ្វើសំណើនៅក្នុងទិន្នានុប្បវត្តិ «Le Cambodge» ថាការដកខ្លួនរបស់កម្ពុជាចេញពីឥទ្ធិពលវប្បធម៌បារាំង នឹងអាចធ្វើឲ្យប្រទេសនេះ មានចំណងរឹងមាំជាមួយនឹងអ្នកជិតខាងរបស់ខ្លួននៅអាស៊ី ។ លោកសាស្ត្រាចារ្យ ថាច់-ថ្វាន់ បានសរសេរបន្ថែមទៀតថា វត្តមាននៅប្រទេសកម្ពុជានៃពួកអ្នកបំរើអង្គការសារពត៌មានបារាំង... ពុំមានផ្តល់ផលប្រយោជន៍អ្វីទាំងអស់ ។ លោកបានពោលថា ពួកអ្នកយកការណ៍ពត៌មានទាំងនេះបានធ្វើយុទ្ធនាការឃោសនាប្រឆាំងប្រទេសកម្ពុជា ម៉្លោះហើយពួកអ្នកទាំងនេះ គួរតែត្រូវបណ្តេញចេញ ។ សារពត៌មានជាភាសាបារាំងមួយទៀត «Le Courrier Phnom Penhois» បានសរសេរថា បើទោះជាប្រទេសបារាំងពុំមានជួយផ្តល់អ្វីដល់យើងក៏ដោយ, ទោះជាជំនួយតាមផ្លូវចិត្តក៏ពុំមានដែរ «យើងមានការធានាជំនួយផ្លូវចិត្តពីប្រទេសមួយទៀតដ៏ធំ ដោយសារតែប្រធានាធិបតីនៃប្រទេសនេះមានវិចារណញ្ញាណភ្លឺស្វាង» គឺជាសេចក្តីសំដៅទៅសហរដ្ឋអាមេរិក ។ «សេចក្តីសំរេចពោរពេញដោយសេចក្តីក្លាហានរបស់លោកប្រធានាធិបតីម្នាក់នេះ នឹងច្បាស់ជាលើកដម្កើងរូបលោកឲ្យមានឋានៈស្មើនឹងប្រធានាធិបតីអាមេរិកាំងធំៗ មានហ្សួជ-វ៉ាស៊ិនតោន និងអាប្រាហាម-លិងកិន», សារពត៌មាននេះបានបន្ថែម ។ ដោយប្រកាសដាក់ទោសបារាំងអំពីបទជួយគាំទ្រ នរោត្តម-សីហនុ, ទិន្នានុប្បវត្តិ «ប្រយោជន៍ខ្មែរ» បានស្នើសុំឲ្យរដ្ឋាភិបាលសើរើឡើងវិញអំពីមិត្តភាពបារាំងខ្មែរ ព្រមទាំងចាត់វិធានការឲ្យសមស្រប ។ តើពួកខ្មែរគួរតែផ្តល់មិត្តភាពទៅដល់ជនជាតិបារាំងដែលធ្លាប់រស់នៅទីនេះតាំងពីយូរយារណាស់មកហើយនោះឬទេ ? ទំនាក់ទំនងរវាងពួកស្ថានទូតបារាំងនៅទីនេះ ហើយនិងខាងអាជ្ញាធរខ្មែរក៏បានមកដល់ទីចប់... មិនត្រឹមតែប៉ុណ្ណោះមានពាក្យចចាមអារាមរាលដាលថា ពួកគេនឹងមានរៀបចំធ្វើបាតុកម្មប្រឆាំងនឹងស្ថានទូតនេះទៀតផង ។

សុភាសិតបារាំងមួយបានបញ្ជាក់ថា ៖ «អ្វីៗដែលថ្មីសុទ្ធសឹងតែល្អទាំងអស់» វាមិនសូវខុសពីភាសិតខ្មែរដែលនិយាយថា «បានថ្មីចោលចាស់» នោះប៉ុន្មានឡើយ

ទាក់ទងនឹងអន្តរគមន៍យោធាចូលក្នុងប្រទេសយើង ពីសំណាក់កងទ័ពនៃរដ្ឋការព្រៃនគរ, នៅទីបំផុតពួកលន់-នល់ក៏បានថ្លែងសារភាពថា គឺខ្លួនគេតែម្តងដែលបានអញ្ជើញពួកនេះឲ្យមកធ្វើដូច្នេះ ។ ក្នុងអត្ថបទខ្សែកាបមួយនៃទីភ្នាក់ងាររ៉ូទែរ ចុះថ្ងៃ២១ឧសភា១៩៧០ នៅព្រៃនគរ ដោយ Christopher Pritchett មានសរសេរថា លោកយ៉ែម-សំបូរពោលថា ទ័ពវៀតណាមខាងត្បូងបានចូលមកច្បាំងនៅប្រទេសកម្ពុជា «តាមសំណើររបស់រដ្ឋាភិបាលខ្មែរ» ហើយប្រទេសកម្ពុជាមានសេចក្តីកត្តញ្ញូតាធម៌ចំពោះជំនួយដ៏រហ័សបែបនេះ ពីសំណាក់សាធារណរដ្ឋវៀតណាម» ។

ការចុះចូលក្នុងបក្សសម្ពន្ធអាមេរិកាំងពីសំណាក់ប្រទេសកម្ពុជារបស់លន់នល់
-សិរិមត: គឺជាទង្វើមួយដែលគេជំរុញលឿនស្លេវទៅមុខដោយចេតនា ហើយដែ-
លពុំបានបកត្រឡប់ថយក្រោយវិញទ្បើយ ។

ក្រុមបក្សអាស៊ាន (សមាគមប្រជាជាតិនៃអាស៊ីភាគអាគ្នេយ៍) ដោយមានគោល
បំណងជួយសង្គ្រោះរបបថ្មីនៃទីក្រុងភ្នំពេញ  កុំឲ្យលិចលង់ស្លាប់ដោយថៀសមិន
រួចនោះ ក៏បានធ្វើសំណើរសំរាប់ថ្ងៃទី១៦និងទី១៧ឧសភា១៩៧០ ឲ្យមានធ្វើសន្និសិ
ទក្នុងចំណោមប្រជាជាតិនៅអាស៊ីនិងប៉ាស៊ីហ្វិកនៅទីក្រុងហ្សាការតា ។ (គួរកត់សំ
គាល់ថា  ពីឆ្នាំ១៩៧៩ទៅ១៩៨១...  សមាគមអាស៊ានដដែលនេះឯងនឹងបានក្លាយ
ទៅជាមូលដ្ឋាន (ចោលម្សៀត) នៃ«សន្និសិទអន្តរជាតិស្តីពីកម្ពុជា» ក្នុងប្រការជួយ
ស្រោចស្រង់របបពួកខ្មែរក្រហម កុំឲ្យលិចលង់វិនាសជាស្ថាពរផងដែរ ។ គិតសព្វ
ៗទៅ  ពួកគេខំប្រឹងប្រែងជួយស្រោចស្រង់នៅប្រទេសកម្ពុជា  កុំឲ្យលិចលង់ស្លាប់
អន្តរធាន នូវក្រុមណាដែលជារបបរាជឃាត ដែលប្រឆាំងសីហនុតែប៉ុណ្ណឹងឯង) ។

«សន្និសិទនៃប្រជាជាតិនៅអាស៊ីនិងប៉ាស៊ីហ្វិក»នេះ  ក៏មិនបានផ្តល់អ្វីដ៏គាប់ប្រ
សើរ ទៅដល់ពួកលន់-នល់និងពួកខ្មែរសាធារណរដ្ឋនោះដែរ ។ ពួករបបថ្មីនៅភ្នំពេ
ញមានសេចក្តីបារម្ភខ្លាចក្រែង តែសន្និសិទដដែលខាងលើនេះ នឹងធ្វើការដោះស្រា
យបញ្ហានយោបាយនៅទីបញ្ចប់ទៅ «ដោយដឹកនាំនរោត្តម-សីហនុ ឲ្យវិលត្រឡប់
មកកម្ពុជាវិញ» តែដដែលដូចលើកមុនៗ ។ បងជីដូនមួយរបស់ខ្ញុំព្រះករុណាខ្ញុំម្ចាក់
ស៊ីសុវត្ថិ-សិរិមត: ហើយនិងរដ្ឋាភិបាលរបស់គាត់ បានបន្ទុកបណ្តាក់ឲ្យបងជីដូនមួ
យម្នាក់ទៀត», ដែលពីដើមធ្លាប់តែប្រួសីហនុណាស់  ប៉ុន្តែដែលក្លាយទៅជាអ្នកប្រ
ឆាំងនឹងសីហនុយ៉ាងសំបើម បន្ទាប់ពីថ្ងៃ១៨មិនា១៩៧០, គឺនរោត្តម-ម៉ូនិស្សារ៉ា (ស្ទូ
មកុំច្រឡំជាមួយនឹងព្រះអង្គម្ចាស់នរោត្តម-ភូរិស្សារ៉ា  ដែលតាមដង្ហែរខ្ញុំព្រះករុណា
ខ្ញុំយ៉ាងស្មោះត្រង់ រហូតដល់ស្លាប់ខ្លួនឯង នៅក្នុងកណ្តាប់ដៃរបស់ពួកខ្មែរក្រហម),
ម៉ូនិស្សារ៉ា, ខ្ញុំព្រះករុណាខ្ញុំសូមបញ្ជាក់  អគ្គលេខាធិការនៃក្រសួងការបរទេសនៃរដ្ឋា
ភិបាលលន់-នល់, បានត្រូវស៊ីសុវត្ថិ-សិរិមត:ប្រើឲ្យធ្វើសេចក្តីថ្លែងការណ៍ក្នុងក្តាំង
រហែកមេឃរហែកដី ទៅកាន់ក្រុមសារពត៌មានអន្តរជាតិ នៅថ្ងៃទី១០ឧសភា១៩៧០
នៅភ្នំពេញ  ដោយបញ្ជាក់ថា  យ៉ាងដាច់ខាតប្រទេសកម្ពុជាមិនត្រូវអនុញ្ញាត  ឲ្យនរោ
ត្តម-សីហនុ  ចូលមករួបរួមស្វះស្វែងរកដំណោះស្រាយក្នុងផ្នែកបញ្ហានយោបាយ
នោះទ្បើយ ។

ក្នុងប្រការនេះ  ខ្ញុំព្រះករុណាខ្ញុំ  សូមអនុញ្ញាតដកស្រង់សេចក្តីក្នុងអត្ថបទមួយ
នៃទីភ្នាក់ងារពត៌មាន យូភីអាយ ដោលមានឈ្មោះអ្នកនិពន្ធ Roxanna Brown ហើ
យដែលមានសំណោរដូច្នេះថា ៖  «...យើងច្បាស់ជាមិនអង្គុយនៅតុចរចាជាមួយគ្នា

និងសម្ដេចសីហនុនោះទេ» ។ មូនិស្សារ៉ាបានពោលបន្ថែមថា ទ្រង់នឹងរង់ចាំថាសន្និសិទអាស៊ី-ប៉ាស៊ីហ្វិក ដែលរៀបចំឡើងនៅហ្សាការតា នឹងច្បាស់ជាផ្ដល់ការគាំទ្ររឹងប៉ឹង ចំពោះជំហររបស់ខ្មែរ ។ សន្និសិទនៅហ្សាការតានឹងច្បាស់ជាគ្មានលទ្ធភាពអ្វីឡើយ ដើម្បីកែប្រែនយោបាយនៃសហរដ្ឋអាមេរិក ក្នុងប្រការផ្ដល់ជំនួយដល់កម្ពុជា, ទ្រង់ពោល «ពីព្រោះយើងកំពុងតែធ្វើការ ដោយមានទំនាក់ទំនងដោយផ្ទាល់ជាមួយនិងអាមេរិកាំង» ។ (...) មូនិស្សារ៉ាបានថ្លែងថា កម្ពុជានឹងស្នើសុំជំនួយពីប្រទេសថៃ នៅពេលដែលរដ្ឋមន្ត្រីការបរទេសយ៉ែម-សំបូរ ធ្វើដំណើរទៅទីនោះក្នុងសប្ដាហ៍នេះ ដើម្បីរៀបចំឲ្យមានទំនាក់ទំនងតាមផ្លូវទូតសាឡើងវិញ ។ ម៉ូនិស្សារ៉ាបានពោលថា ទ្រង់មិនមានជំនឿទេ មកដល់ថ្នាក់នេះទៅហើយ ថាសហភាពសូវៀតនឹងធ្វើដំណើរទៅតាមប្រទេសកុម្មុយនិស្តខ្លះៗ ដោយធ្វើការផ្ដាច់ចំណងទូតជាមួយនឹងទីក្រុងភ្នំពេញ ។ ទ្រង់យល់ថា ពួករុស្ស៊ីមិនចង់លេងល្បែងចូលស៊ីងរបស់ពួកកុម្មុយនិស្តចិននោះឡើយ ។

ទាក់ទងនឹងអាកប្បកិរិយាប្រឆាំងនឹងហ៊្វងនិងគ្រុង (រណសិរ្សនិងរាជរដ្ឋាភិបាលក្រហមរបស់ស្ដេចសីហនុនៅប៉េកាំង) ពីសំណាក់សហភាពសូវៀត, ម៉ូនិស្សារ៉ាគាត់មិនបានធ្វើការភ័ន្តច្រឡំនោះទេ ។ ពួករុស្ស៊ីហើយនិងក្រុមរណបរបស់ខ្លួនទាំងអស់ លើកលែងតែប្រទេសគុយបាមួយចេញ, នឹងស្ថិតនៅខាងពួក«សាធារណរដ្ឋខ្មែរ» រហូតដល់ចុងចប់ ។

ក៏ប៉ុន្តែ ភ្លាមបន្ទាប់ពីការប្រកាសនៅថ្ងៃ៥ឧសភាឆ្នាំ១៩៧០ នូវការបង្កើតរដ្ឋាភិបាលថ្មីរបស់ខ្ញុំព្រះករុណាខ្ញុំ(គ្រុង) ដែលមានសម្ដេចប៉ែន-នុតជាប្រធាន, ប្រទេសទាំងឡាយដូចតទៅនេះ ដែលធ្លាប់មានស្ថានទូតនៅទីក្រុងភ្នំពេញ ក៏បានកាត់ផ្ដាច់ចំណងពីរបបលន់នល់-សិរិមតៈ គឺមាន ៖ ប្រទេសចិន, សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ, គុយបា, សាធារណរដ្ឋប្រជាមានិតុវៀតណាមខាងត្បូង (យៀកកុង), សាធារណរដ្ឋអារ៉ាប់រួម (អេយីព្ទ), សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (ខាងជើង) យូហ្គោស្លាវី ។ ពួកភ្នាក់ងារទូតតំណាងប្រទេសទាំអស់នេះ ពោលគឺពួកដែលមិនទាន់បានចាកចេញពីប្រទេសកម្ពុជា បន្ទាប់ពីរដ្ឋប្រហារថ្ងៃទី១៨មិនានោះនៅឡើយទេ, ក៏ចាប់ផ្ដើមចាកចេញដោយគ្មានបង្អង់ពីប្រទេសកម្ពុជានៃពួកជនក្បត់ ។ សាធារណរដ្ឋប្រជាមានិតុចិនក៏បានបញ្ជូនពួកក្រុមទូតមួយក្ដាប់តូច ឲ្យវិលត្រឡប់ទៅភ្នំពេញវិញ ដែលកាលពីដើមធ្លាប់តែបំរើសីហនុ ហើយដែលឥឡូវក្លាយទៅជាពួកប្រួលន់នល់ បន្ទាប់ពីថ្ងៃទី១៨មិនា ហើយចិនក៏ទទួលយកភ្នាក់ងារទូតរបស់គេដែលនៅភ្នំពេញនោះ ឲ្យត្រឡប់មកវិញ ។ មកដល់ទីក្រុងប៉េកាំង, ពួកភ្នាក់ងារទូតចិនទាំងនេះក៏បានថ្លាថ្លែងប្រាប់ខ្ញុំព្រះករុណាខ្ញុំ អំពីបណ្ដាំនៃពួកបណ្ដាជននិងពួកយោធាជាច្រើ

នថា ពួកគេនៅតែស្មោះស្ម័គ្រជានិច្ចជាមួយនិងសម្តេចសីហនុ រហូតដល់ក្រអៅនៃបេះដូង» បើទោះជាពួកគេត្រូវរស់បណ្តោះអាសន្នសិន នៅពេលអវត្តមាននៃសម្តេចនៅក្នុងមាតុប្រទេស ហើយបើទោះពួកគេត្រូវមានកាតព្វកិច្ចស្រែកលូម្តងម្កាលជាមួយនឹងពួកក្រុមឆ្កែចចកក៏ដោយ ។

អំពីរដ្ឋដទៃទៀត ដែលមានឋានៈជា«ក្រុមមិត្តភក្តិតាំងពីដំបូងទី» របស់គ្រុង, ដែលបានទទួលស្គាល់រដ្ឋាភិបាលនេះនៅក្នុងឆ្នាំ១៩៧០ ហើយដែលបដិសេធមិនឲ្យមានការទាក់ទងទាល់តែសោះជាមួយនឹង«សាធារណរដ្ឋខ្មែរ» មានប្រទេស ៖ អាលបានី, អាល់ហ្សេរី, អាហ្វ្រិកកណ្តាល, កុងហ្គោ (ប្រាសហ្សាវីល) , គីណេ, អៀរ៉ាក់, លីប៊ី, ម៉ូរីតានី, ប៉ាឡេសទីន, រូម៉ានី, សូម៉ាលី, យេមែនខាងជើង, យេមែនខាងត្បូង, ស៊ូដង់, សៀរី, តង់ហ្សានី ។

តទៅនេះជាសេចក្តីអត្ថាធិប្បាយរៀបរាប់អំពីគ្រុង ដោយអ្នកនិពន្ធ Jean Lacouture (នៅក្នុងទស្សនាវដ្តី «ឡឺ នូវែល អុបសែរវ៉ាទើរ» ចុះផ្សាយពីថ្ងៃ៩ទៅថ្ងៃ១០ ឧសភា១៩៧០) ៖

«នៅពេលដែលព្រះអង្គយាងត្រឡប់ពីខេត្តកន្តាំងវិញ, ហើយបន្ទាប់ពីមេដឹកនាំខ្មែរកុម្មុយនិស្តដ៏ឆ្នើមម្នាក់, លោកជួន-មុម, បានធ្វើដំណើរពីក្រុងប៉ារីសមកដល់ប៉េកាំង ទើបសម្តេចសីហនុមានលទ្ធភាពចំណាយកម្លាំងព្រះអង្គ ក្នុងការបង្កើតរដ្ឋាភិបាលមួយនិងគណបក្សមួយ ដែលចាប់ផ្តើមធ្វើការតស៊ូតទល់នឹងការរាតត្បាតរបស់អាមេរិកាំងនិងបរិវារនៅទីក្រុងភ្នំពេញ ។ គណបក្សនោះមានឈ្មោះថា ហ៊្វុង (រណសិរ្សរួបរួមជាតិកម្ពុជា) ។ វាមានភិនភាគបីយ៉ាងដែលយើងគួរកត់សម្គាល់ ។ ភិនភាគម៉្យាងគឺគណបក្សនេះមានមូលដ្ឋានចំបងរបស់ខ្លួនឯងរួចទៅហើយ នៅក្នុងព្រៃម៉ាគីផ្នែកខាងត្បូងនិងខាងលិចនៃភ្នំក្រវ៉ាញនិងបាត់ដំបង ។ នៅក្នុងភិនភាគម៉្យាងទៀត គឺគណបក្សនេះបានផ្តាច់ខ្លួន ពីសាមគ្គីភាពជាតិទូលំទូលាយជាទូទៅបែបយល់សប្តិយល់សូងរបស់សង្គម(រ៉ាស្រ្តនិយម)នៃសម្តេចសីហនុ, ក៏ប៉ុន្តែគណបក្សនេះផ្តោតគំនិតទៅលើការរួបរួម ដោយធ្វើការអំពាវនាវស្រែកហៅរកកម្លាំងផ្សេងៗបីគ្រប់ទិសទីនៃសង្គម, យោងតាមឧទាហរណ៍នៃពួករណសិរ្សរំដោះ (យៀកកុង) នៃវៀតណាមខាងត្បូង ។ នៅទីបំផុត គណបក្សនេះបានបង្ហាញនូវកម្មវិធីនយោបាយមួយប្រកបដោយសេចក្តីសុភាពរាបសារដ៏ច្រើន ដែលកម្មសិទ្ធិទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងលទ្ធិព្រះពុទ្ធសាសនា ត្រូវមានការធានារ៉ាប់រង ដែលជាកត្តានៃការរីកចំរើនដ៏ឆាប់រហ័សនៃជីវិតនយោបាយ ។ ទោះជាយ៉ាងណាក្តី សមាសភាពនៃរដ្ឋាភិបាលដែលចេញមកពីហ៊្វុង (គ្រុង ៖ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា...ន.ស.) គឺបានបង្ហាញនូវអត្ថន័យដ៏បរិបូណ៌ ។ សមាជិកទាំងអស់នៃរដ្ឋាភិបាលនេះ ដែលវាខុស

ពីជំហានដំបូងនៃក្រុមប្រឹក្សាដឹកនាំនយោបាយរបស់ពួក F.N.L. (យៀកកុង) គឺសុទ្ធសឹងតែជាមនុស្សដែលគេធ្លាប់ស្គាល់ពេកណាស់ទៅហើយ ។ ទោះជាអ្នកនយោបាយមាននិន្នាការ ម៉ារគសុីស្ត (កុម្មុយនិស្ត) ឬមិនមែនក៏ដោយ ពួកគេសុទ្ធសឹងតែធ្លាប់បានដើរតួសំខាន់ៗក្នុងជីវិតនយោបាយនៃប្រទេសជាតិ ចំនួនជាង១០ឆ្នាំមកហើយ ។ ជាដំបូងគឺលោកនាយករដ្ឋាភិបាល លោកប៉ែន-នុត ដែលមានលក្ខណៈចំពោះរាជានិយមខ្មែរ ដូចជាលោក Aristide Briand ចំពោះសាធារណរដ្ឋទី៣នៃប្រទេសបារាំង, គឺមានលក្ខណៈជានិរន្តរភាពនិងជានិមិត្តរូប ប្រកបដោយបញ្ញានិងការសិ្ទតស្វាញ... ប្រហែលគ្នានិងលក្ខណៈរុក្ខជាតិអញ្ចឹងខ្លះដែរ ។ នៅក្បែររូបលោកមានមនុស្សបីក្រុម ។ ទី១ គឺពួកអ្នករាជការសីហានុនិយមជាន់ខ្ពស់ ដែលគ្មាននិន្នាការនយោបាយច្បាស់លាស់ ដូចជាអតីតរាជទូតនៅទីក្រុងមូស្គូ, តែរ និងជាការ...ដូចជាលោកចៅ-សេង ដែលធ្លាប់ធ្វើជារដ្ឋមន្ត្រីនៅភ្នំពេញ ហើយសព្វថ្ងៃនេះនៅប៉េកាំង នៅពេលណាដែលគាត់នឹងបង្ហាត់បង្រៀនអំពីសង្គមនិយមនយោបាយទៅ Perpignan, (...) ដូចជាលោកជួន-មុម វិស្វករខ្មែរផ្នែកខាងពហុបច្ចេកទេសតែម្នាក់គត់ ដែលបានចាកចោល C.N.R.S. (មជ្ឈមណ្ឌលស្រាវជ្រាវនៃប្រទេសបារាំង) ដើម្បីបំពេញមុខងារជារដ្ឋមន្ត្រីផ្នែកហិរញ្ញវត្ថុនៅក្នុងរដ្ឋាភិបាលនេះ ។ នៅទីបំផុតគឺមានពួកព្រៃម៉ាគី ដែលមានមេដឹកនាំធំៗ៣នាក់, លោកហ៊ូ-យន់,ហ៊ូ-នឹម និងខៀវសំផន ដែលបានទទួលបន្ទុករៀងៗខ្លួន នូវទីស្តីការផ្នែកខាងមហាផ្ទៃ, ឃោសនាការ និងការពារប្រទេស ។ គឺវរជនខាងលើទាំងនេះ ដែលត្រូវប្រឈមមុខតតាំងជាមួយនឹងលន់-នល់» ។

មុននឹងរៀបចំផមាន (រដ្ឋាភិបាល) គ្រុង, (រណសិរ្ស) ហ៊្វុង បានតាក់តែងចេញរូបរាងក្នុង «កម្មវិធីនយោបាយ»មួយយ៉ាងប្រណិតដ៏គួរឲ្យរំភើប ប្រកបដោយលក្ខណៈ«ត្រឹមត្រូវ, ប្រាកដនិយម និងស្របតាមលទ្ធិប្រជាធិបតេយ្យ» ។

ពួកបញ្ញាជនបារាំងផ្នែកខាងឆ្វេង បានធ្វើសេចក្តីសរសើរ «កម្មវិធីនយោបាយ» នេះដោយស្មោះអស់ពីដួងចិត្ត ដោយហេតុថា ជាទង្វើរបស់បញ្ញាជនខ្មែរក្រហមដោយមានជួន-មុមជាមេខ្លោង ហើយដែលមិត្តភក្តិបារាំងខាងឆ្វេងរបស់ពួកគេចាត់ទុកថា ជាក្រុមបក្សជនប្រជាធិបតេយ្យដ៏ពិតប្រាកដ... មិនត្រឹមតែប៉ុណ្ណោះ បានធ្លាប់ជួយគាំទ្រពួកអ្នកទាំងនេះ ក្នុងការតស៊ូប្រយុទ្ធផ្នែកនយោបាយ ប្រឆាំងនឹង«របបសក្តិភូមិ, លទ្ធិជិះជាន់ផ្តាច់ការ, អំពើពុករលួយ» របស់ខ្ញុំព្រះករុណាខ្ញុំ ។

កម្មវិធីនយោបាយរបស់ហ៊្វុង បានត្រូវរៀបចំតាក់តែងឡើង តាំងពីអក្សរ«ក» រហូតដល់«អ» ដោយលោកវិស្វករពហុបច្ចេកទេស (Polytechnicien) ខ្មែរតែម្នាក់គត់, គឺលោកជួន-មុមដ៏ឆ្នើម ដែលធ្លាប់មានពូជអំបូរជាក្រុមវាំង ក្លាយខ្លួន

មកជា«វណ្ណៈអធន» ដើម្បីបំរើក្រុមបក្សឲ្យសមស្របតាមកាលៈទេសៈនៃសេចក្ដីត្រូវការរបស់ពួកខ្មែរក្រហម ។ ខ្ញុំព្រះករុណាខ្ញុំសូមបើកវង្វង់ក្រចកទៅចុះ...រឿងទាំងអស់នេះមិនបានហាមឃាត់លោកជួន-មុម ឲ្យយកប្រពន្ធបារាំងម្នាក់យ៉ាងស្អាតប្រិមប្រិយ ដែលមានលក្ខណៈអភិជនតាំងពីក្បាលដល់ចុងជើង ។

លោកជួន-មុមបានរៀបរៀងកម្មវិធីនេះឡើង យោងតាមសំណូមពររបស់ពួកក្រុមសមមិត្តរបស់គាត់ ដែលបំរើ«ការតស៊ូផ្ទៃក្នុង» មានខៀវ-សំផន និងអៀង-សារី ។ល។ មិង ។ល។ ដែលចាប់ផ្ដើមពីឆ្នាំ១៩៧៥ឡើងទៅ បានលេចឡើងជាមេព្រាយបិសាច ដែលមិនត្រឹមតែស្រេកឃ្លានអំណាចអធម៌ ដែលប្រឆាំងនឹងប្រជាជនខ្លួនឯងនិងលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងស្រេកឃ្លានលោហិតនៃប្រជាពលរដ្ឋខ្មែរស្លូតត្រង់ថែមទៀត ។

គឺជាការពិតណាស់ កាលក្នុងឆ្នាំ១៩៧០ ទាំងពួកបញ្ញាជនបារាំងខាងឆ្វេង និងខ្ញុំព្រះករុណាខ្ញុំ ពុំបាននឹកស្មានសោះតែម្ដង, សូម្បីតែមួយនាទីក៏គ្មានដែរ, ថាពួកខ្មែរក្រហមទាំងនេះ បានក្លាយទៅជាព្រាយបិសាចអាក្រក់អាក្រីជាងអារក្សសាតាំងទៅទៀត (Satan) ។ មេអារក្សសាតាំងក្រោយនេះ មានកំពស់កំពរមិនបានបាតជើងរបស់ពួកខ្មែរក្រហមផងឡើយ ក្នុងប្រការនៃលក្ខណៈឃោរឃៅ, អំពើក្រឡិចក្រឡុច និងនយោបាយបោកប្រាស់...។

<u>កម្មវិធីនយោបាយរបស់ពួកហ៊្វុង</u> ដែលពួកអ្នកគាំទ្រទាំងឡាយ, ដោយមានរាប់ខ្ញុំព្រះករុណាខ្ញុំនិងសម្ដេចប៉ែន-នុតផងដែរ, បានថ្លែងសរសើរដល់កំពូល, បានក្លាយទៅជា, តាំងពីមុនពេលជោគជ័យទាំងស្រុងនៃពួកខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ទៅទៀត, កម្មវិធីបោកបញ្ឆោតមួយដ៏ធំសំបើម, ទាក់ទងនឹងប្រជារាស្ត្ររបស់យើងផងនិងទាក់ទងនឹងពិភពខាងក្រៅនៅហផង ជាពិសេសចំពោះពួកមិត្តភក្ដិបារាំង ហើយនិងពួកអ្នកដទៃទៀត ដែលធ្លាប់ពឹងផ្អែកសេចក្ដីសង្ឃឹមដ៏ធំធេងទៅលើតស៊ូរំដោះរបស់ពួកយើង ដើម្បីស្ថាបនាកិច្ចការកសាងជាតិ, បន្ទាប់ពីមានជោគជ័យទៅ, ដើម្បីសាងសងប្រទេសកម្ពុជាមួយឲ្យបានសំបូរសប្បាយរុងរឿង ប្រកបដោយលទ្ធិប្រជាធិបតេយ្យ និងពោរពេញដោយយុត្តិធម៌នៃសង្គម» ។

ក៏ប៉ុន្តែដោយគ្មាននរណាម្នាក់អាចសម្លឹងមើលឃើញ ឬទស្សន៍ទាយអំពីអនាគតបាន កាលក្នុងខែឧសភា-មិថុនា១៩៧០ យើងក៏នាំគ្នារស់នៅក្នុងការសប្បាយយល់សប្តិយល់សួងដូចច្នេះសិនទៅ ។

ក្នុងប្រការនេះ, លោក **Jacques Decornoy** បានសរសេរអត្ថបទដ៏ប្រណិត ដ៏គួរឲ្យកត់សម្គាល់ ចុះផ្សាយនៅក្នុង **Le Monde Diplomatique** (ខែឧសភាឆ្នាំ១៩៧០) ៖

«ដើម្បីទប់ទល់នយោបាយ(បរបក្ស) ពួកអ្នកជាតិនិយមខ្មែរនៅជុំវិញសម្តេចសីហនុ ព្រមទាំងពួកកុម្មុយនិស្ត បានសំដែងបង្ហាញអំពីកម្មវិធីនយោបាយមួយ ដែលមានដាក់លាយឡំគ្នា នូវឧត្តមគតិជាតម្លៃពីបុរាណកាលមករបស់ព្រះប្រមុខរដ្ឋទាក់ទងនឹងធាតុពិតនៃរបប ហើយនិងក្រាំងបញ្ជីនៃវិធានការណ៍មួយចំនួនសំរាប់ចាត់ចែង ដែលទៅមិនហួសឆ្ងាយប៉ុន្មានពីការកែទម្រង់មួយដ៏ប្រយ័ត្នប្រយែងតែប៉ុណ្ណោះ ។ យើងឃិតនៅសែនឆ្ងាយពីផែនការដែលសំដែងបង្ហាញដោយរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃវៀតណាមខាងត្បូង (វៀតកុង) ដែលទាមទារឲ្យដោះដូររដ្ឋធម្មនុញ្ញនិងស្ថាប័នជាតិទាំងអស់នៃរដ្ឋាភិបាលព្រៃនគរ ។ នៅក្នុងប្រការនេះ ប្រទេសកម្ពុជានៅតែមានលក្ខណៈ ជាព្រះរាជាណាចក្រ..តែពុំមានព្រះរាជាតែប៉ុណ្ណោះឯង ហើយដែលមានព្រះពុទ្ធសាសនា ជាលទ្ធិសាសនារបស់រដ្ឋ ។ ទោះជាយ៉ាងនេះក្តី គេត្រូវសន្មត់ថា ប្រទេសជាតិត្រូវធ្វើដំណើរវិវឌ្ឍន៍ឆ្ពោះទៅរកសេរីភាពពិតប្រាកដ- មិនមែនតែយ៉ាៗផ្តែកសំបកក្រៅតែប៉ុណ្ណោះទេ គឺដោយហេតុថាកម្មវិធីនោះបាននិយាយពី «ប្រជាធិបតេយ្យនិយម ដែលកំពុងតែផ្សព្វផ្សាយនៅក្នុងតំបន់រំដោះ» ។ (មិត្តរបស់យើង ដែលនៅក្នុងចំណោមបញ្ញាជនបារាំងខាងឆ្វេង មានជំនឿទាំងស្រុង ដោយគ្មានសេចក្តីសង្ស័យ សូម្បីតែបន្តិចបន្តួច ថាពួកខ្មែរក្រហមស្រឡាញ់លទ្ធិប្រជាធិបតេយ្យជាងស្តេចសីហនុ ។ ម្ល៉ោះហើយ សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋយើង នឹងច្បាស់ជាមានសភាពពិតប្រាកដ ពុំមែនមានទ្រង់ទ្រាយ «បោកបញ្ឆោត» ដូចកាលសម័យសីហនុនោះឡើយ ។ ម្ល៉ោះហើយជំនឿនេះ វានឹងក្លាយទៅជាការយល់ខុសតាំងស្រុង បើគេសម្លឹងមើលទៅអ្វីៗ ដែលកើតឡើងនៅក្រោមអង្គការដ៏«មហាភ្លឺស្វាង, មហាត្រឹមត្រូវ, មហាលោតផ្លោះ, មហាអស្ចារ្យ»នៃក្រុមបក្សប៉ុល-ពត, អៀង-សារី, ខៀវ-សំផន, សុន-សេន, នួន-ជា... ន.ស.) ។

ចំណែកឯគំរោងវិធានការណ៍ទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ដែលមានសរសេរនៅក្នុងកម្មវិធីនៃរណសិរ្សរួបរួមជាតិកម្ពុជា បានលេចឡើងជាសំណើរមានប្រយោជន៍ ដោយហេតុថាពួកគេ បានធ្វើសំណូមពរឲ្យមានការកែទម្រង់ក្នុងការជួយសង្គ្រោះពួកប្រជាកសិករ ៖ កម្មសិទ្ធិផ្ទាល់ខ្លួនត្រូវបានទទួលការធានា (តាមការពិត ការធានានេះនឹងលេចឡើងជាការលួចប្លន់ទាំងស្រុង... គឺជាការដកហូតរឹបអូសដល់ឫសគល់តែម្តង ន.ស.), ការស្វែងរកដំណោះស្រាយមួយដ៏សមរម្យ ទាក់ទងនឹងបំណុលប្រាក់ប្រកបដោយអយុត្តិធម៌» ។ល។ តាំងពីបុរាណកាលមក ពួកប្រជាកសិករនៅអាស៊ី តែងតែទទួលរងគ្រោះដោយពួកឲ្យខ្ចីបុល, ពួកអ្នកឲ្យខ្ចីប្រាក់តែយកសំណងជាផលិតផល, ម្ល៉ោះហើយកំរោងការណ៍បែបនេះ អាចជួយសង្គ្រោះសកម្មភាពនៃរណសិរ្សរំដោះ ហើយធ្វើឲ្យមនុស្សចូលចិត្តច្រើនជាងគំរោងការណ៍របស់ឧត្តម

សេនីយ៍លន់-នល់ ដែលចាំតែស្រែកប្រកាសតែអំពីសាធារណរដ្ឋ ។ (តាមពិតការ«តាំងឲ្យមានរបបសាធារណរដ្ឋ»របស់ពួកលន់-នល់, និងការ«តាំងឲ្យមានរបបប្រជាធិបតេយ្យនិងការរំដោះពួកប្រជាពលកររបស់យើងឲ្យរួចខ្លួនពីអ្នកឲ្យខ្ចីប្រាក់ (ចិនព្រិន)» ដោយពួកខ្មែរក្រហម, គឺមានលំនាំស្រដៀងគ្នា ដូចទឹកពីរដំណក់ក្នុងប្រការដែលថា ពួកឆ្វេងនិយមបំផុតនិងពួកស្តាំនិយមបំផុតរបស់យើង តែងមើលងាយមើលស្រាលប្រជាពលរដ្ឋតូចតាចរបស់យើងយ៉ាងខ្លាំង ហើយមិនញញើតញញើមក្នុងការបោកប្រាស់យ៉ាងរបៀបយង់ឃ្នងនោះឡើយ ។ ជាការពិត ពួកខ្មែរក្រហមបានចាប់ផ្តើមពិឃាតពួកអ្នកឲ្យខ្ចីប្រាក់ ហើយបន្ទាន់មកទៀត ពួកគេក៏ពិឃាតផងដែរនូវពួកប្រជាកសិករ ដែលមិនចង់ធ្វើការរបៀបជាកញ្ជះដាច់ថ្លៃរបស់អង្គការ«ប៉ុល-ពត» ព្រមទាំងតាមសម្លាប់រហូតដល់ពួករាជានិយម និងពួកអ្នកកាន់លទ្ធិព្រះពុទ្ធសាសនាថែមទៀត ដែលកម្មវិធីនយោបាយរបស់ពួកហ្នឹងបានបញ្ជាក់ថា ពួកគេនៅតែមានការគោរពជានិច្ច ! ន.ស.) ។ គួរកត់សម្គាល់ដែរថា អ្នកនិពន្ធនៃកម្មវិធីបានសំដែងឆន្ទៈចង់ឲ្យស្រុកខ្មែរចេញផុតពីសករាជនៃអាណានិគមនិយម ដោយជំរុញឲ្យមានខេមរយានកម្មជឿនលឿនទៅមុខយ៉ាងសកម្មក្នុងមជ្ឈដ្ឋានសិក្សាធិការ (ខេមរយានកម្មមានដំណើរលឿនទៅមុខណាស់ទៅហើយ មុនពេលរដ្ឋប្រហារក្រោមការណែនាំរបស់សម្តេចសីហនុ ហើយនិងរដ្ឋមន្ត្រីក្រសួងសិក្សាធិការដ៏ក្មេងម្នាក់ ប្រកបដោយថាមពល)...ព្រមទាំងធ្វើសេចក្តីស្រាវជ្រាវទាក់ទងនឹងសាវតាររបស់ជាតិ «ដែលជាច្រើនដងណាស់ មានទ្រង់ទ្រាយខុសពីសេចក្តីពិត ដោយសារតែពួកអ្នកនិពន្ធបរទេស» ៖ ដោយសន្សឹមៗនិងយ៉ាងស្ងាត់ស្ងៀម មុខការនេះបានត្រូវបំពេញដោយពួកបញ្ញវ័ន្តជឿនលឿនខ្លះនៅប្រទេសបារាំង ។ (សេចក្តីពិតបង្ខំឲ្យខ្ញុំព្រះករុណាខ្ញុំបញ្ជាក់ថា ពួកបញ្ញាជនខាងឆ្វេងរបស់យើង ដូចជាពួកបញ្ញាជនខាងស្តាំដូច្នោះដែរ ពុំដែលនឹកឃើញចង់សរសេរអំពីប្រវត្តិសាស្ត្រនៃប្រទេសយើងឲ្យស្របតាមសេចក្តីពិតនោះទេ ។ ពួកគេបានធ្វើការតិះទៀនទៅលើពួកអ្នកនិពន្ធប្រវត្តិវិទ្យាបរទេស ដោយសារតែពួកនេះមិនបានសរសេរបង្អាប់រាជានិយមនិងស្តេចខ្មែរឲ្យបានខ្មៅងងឹតគ្រប់គ្រាន់តែប៉ុណ្ណោះ ។ ពីចន្លោះឆ្នាំ១៩៧៥ទៅ១៩៧៩, គេអាចស្តាប់វិទ្យុរបស់ខ្មែរក្រហម ក៏ដឹងបានដែរថា តើពួកគេសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជាបែបណា ដើម្បីកែប្រែពីទ្រង់ទ្រាយខុសនៃពួកអ្នកនិពន្ធបរទេស ។ ចំណែកឯពួកបញ្ញាជនផ្នែកខាងស្តាំបំផុតរបស់យើងវិញ អាចបំភ្លៃសាវតាជាតិយើងឲ្យប្រាសចាកសេចក្តីពិត ក៏មិនសូវជាចាញ់ពួកប៉ុល-ពតប៉ុន្មានដែរ ! នៅចុងចប់ទៅ គួរកត់សម្គាល់ថា ទាក់ទងនឹង «ខេមរយានកម្ម»នៃសិក្សាធិការរបស់ពួកខ្មែរក្រហម ៖ ពួកគេខំប្រឹង «ខេមរយានកម្ម» ខ្លាំងពេកទៅ រហូតទាល់តែគេពុំបានបង្ហាត់បង្រៀន

អ្វីទាល់តែសោះដល់កូនចៅរបស់យើង... មិនត្រឹមតែប៉ុណ្ណោះ ធ្វើឲ្យពួកក្រោយនេះក្លាយទៅជាពួកអវិជ្ជានិងខ្ញុំកញ្ជះគេសុទ្ធសាធ ។ នៅថ្នាក់កំពស់កំពររបស់រដ្ឋវិញ «ខេមរយានកម្ម»របស់ពួកគេ បានក្លាយទៅជាការប្រកាន់និងការមាក់ងាយពូជសាសន៍ ។ គឺពួកខ្មែរក្រហមបានហាមឃាត់ពិភពលោកទាំងមូល មិនឲ្យហៅប្រទេសកម្ពុជាថា «Cambodge» ឬ «Cambodia» អ្វីទេ ថ្វីបើខាងសាធារណរដ្ឋប្រជាមានិតចិនវិញ, ដែលមានឈ្មោះជាចិនថា «ឈុង-គួ», ចិនសុខចិត្តឲ្យគេហៅនៅអ.ស ប.ថា «Chine» ឬ «China», ឬជាភាសារុស្ស៊ីថា «Kitai» ។ល។

ទោះជានៅក្នុងឆ្នាំ១៩៨១ទៅហើយក្តី V.O.A. (វិទ្យុសម្លេងសហរដ្ឋអាមេរិក) និង B.B.C. (វិទ្យុសម្លេងចក្រភពអង់គ្លេស)... ក៏មានកាតព្វកិច្ចចៀសវាងហៅប្រទេសខ្មែរថា«Cambodia» នោះដែរ ដោយប្រើពាក្យថា «Kampuchea» ជំនួសវិញ ។ ការជំកើងខ្លួនហួសហេតុដូច្នេះ គឺជាទ្រង់ទ្រាយមួយនៃការប្រកាន់ពូជសាសន៍ ដ៏ប្រកបដោយគ្រោះថ្នាក់បំផុត ។ ឧទាហរណ៍នៃសាវតារបស់អ៊ីត្លែរ ជាការច្បាស់ក្រឡែត ៖ ពួកអ្នកប្រវត្តិវិទ្យាពិតប្រាកដ បានដឹងហើយថា តើការមាក់ងាយពូជសាសន៍រំជើបរំជួលនោះ វាអាចដឹកនាំទៅដល់ទីណាដែរ ។ ការប្រឹងប្រែងបែបនេះបានត្រូវចាប់ផ្តើមឡើង ចាប់តាំងពីឥឡូវនេះទៅ ស្របគ្នាជាមួយនឹង«ការរំដោះ»នៃប្រទេសជាតិ ៖ គេទទួលស្គាល់ថា ចំណាត់វិធានការណ៍បែបនេះ ក៏ជាទីចូលចិត្តរបស់ពួកអ្នកតស៊ូវៀតណាម (យៀកកុង) ដែលយល់ថាការសាងសង់សង្គមថ្មី វាត្រូវទៅស្របជាមួយគ្នា នឹងការប្រយុទ្ធខាងផ្នែកកងទ័ពនិងខាងផ្នែកនយោបាយ ។ គួរកត់សម្គាល់ដែរថា នៅក្នុងរដ្ឋាភិបាលដែលរៀបចំឡើងដោយលោកប៉ែន-នុត, ពួកកុម្មុយនិស្ត ឬពួកដែលគេស្គាល់ថាមានឈ្មោះអីចឹង បានក្តោបក្តាប់ក្រសួងសំខាន់ៗអស់រលីងទៅហើយ ៖ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងការពារជាតិ, ពត៌មាននិងឃោសនា, ក្រសួងមហាផ្ទៃ និងកែទម្រង់ជនបទ»...

អ្វីទាល់តែសោះដល់កូនចៅរបស់យើង... មិនត្រឹមតែប៉ុណ្ណោះ ធ្វើឲ្យពួកក្រោយនេះក្លាយទៅជាពួកអវិជ្ជានិងខ្ញុំកញ្ជះគេសុទ្ធសាធ ។ នៅថ្នាក់កំពស់កំពូលរបស់រដ្ឋវិញ «ខេមរយានកម្ម»របស់ពួកគេ បានក្លាយទៅជាការប្រកាន់និងការមាក់ងាយពូជសាសន៍ ។ គឺពួកខ្មែរក្រហមបានហាមឃាត់ពិភពលោកទាំងមូល មិនឲ្យហៅប្រទេសកម្ពុជាថា «Cambodge» ឬ «Cambodia» អ្វីទេ ថ្វីបើខាងសាធារណរដ្ឋប្រជាមានិតចិនវិញ, ដែលមានឈ្មោះជាចិនថា «ឈុង-គួ», ចិនសុខចិត្តឲ្យគេហៅនៅអ.ស.ប.ថា «Chine» ឬ «China», ឬជាភាសារុស្ស៊ីថា «Kitai» ។ល។

ទោះជានៅក្នុងឆ្នាំ១៩៨១ទៅហើយក្តី V.O.A. (វិទ្យុសម្លេងសហរដ្ឋអាមេរិក) និង B.B.C. (វិទ្យុសម្លេងចក្រភពអង់គ្លេស)... ក៏មានកាតព្វកិច្ចចៀសវាងហៅប្រទេសខ្មែរថា«Cambodia» នោះដែរ ដោយប្រើពាក្យថា «Kampuchea» ជំនួសវិញ ។ ការជំកើងខ្លួនហួសហេតុដូច្នេះ គឺជាទ្រង់ទ្រាយមួយនៃការប្រកាន់ពូជសាសន៍ ដ៏ប្រកបដោយគ្រោះថ្នាក់បំផុត ។ ឧទាហរណ៍នៃសាវតាររបស់អ៊ីត្លែរ ជាការច្បាស់ក្រឡែត ៖ ពួកអ្នកប្រវត្តិវិទ្យាពិតប្រាកដ បានដឹងហើយថា តើការមាក់ងាយពូជសាសន៍រំជើបរំជួលនោះ វាអាចដឹកនាំទៅដល់ទីណាដែរ ។ ការប្រឹងប្រែងបែបនេះបានត្រូវចាប់ផ្តើមឡើង ចាប់តាំងពីឥឡូវនេះទៅ ស្របគ្នាជាមួយនឹង«ការរំដោះ»នៃប្រទេសជាតិ ៖ គេទទួលស្គាល់ថា ចំណាត់វិធានការណ៍បែបនេះ ក៏ជាទីចូលចិត្តរបស់ពួកអ្នកតស៊ូវៀតណាម (យៀកកុង) ដែលយល់ថាការសាងសង់សង្គមថ្មី វាត្រូវទៅស្របជាមួយគ្នា នឹងការប្រយុទ្ធខាងផ្នែកកងទ័ពនិងខាងផ្នែកនយោបាយ ។ គួរកត់សម្គាល់ដែរថា នៅក្នុងរដ្ឋាភិបាលដែលរៀបចំឡើងដោយលោកប៉ែន-នុត, ពួកកុម្មុយនិស្ត ឬពួកដែលគេស្គាល់ថាមានឈ្មោះអីចឹង បានក្តោបក្តាប់ក្រសួងសំខាន់ៗអស់រលីងទៅហើយ ៖ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងការពារជាតិ, ពត៌មាននិងឃោសនា, ក្រសួងមហាផ្ទៃ និងកែទម្រង់ជនបទ»...

សេចក្តីសន្យាដ៏ល្អៗរបស់ពួកខ្មែរក្រហម ក៏ដូចតែសេចក្តីសន្យាដ៏អស្ចារ្យៗរបស់ពួកយៀកកុង ទៅកាន់ប្រជាពលរដ្ឋរបស់ពួកគេដូច្នោះដែរ... បន្ទាប់ពីបីបួនឆ្នាំនៃជីវិតពិសោធន៍ទៅ ក៏បានលេចឡើងជាការគួរឲ្យខកចិត្តខ្លាំងណាស់ ។ ជាពិសេសចំពោះពួកខ្មែរក្រហម, ការអនុវត្តន៍នៃជីវិតពិសោធន៍បែបដូចនេះ បានទទួលលទ្ធផលជាទីចុងចប់ទៅ នូវសោកនាដកម្មដ៏ពោរពេញដោយថ្លុកឈាម ដ៏មហាសែនអាម៉ាស់នៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ។ ចំពោះរឿងនេះ អ្វីៗដែលនៅសល់សំរាប់ Jean Lacouture, Jacques Decornoy, នរោត្តម-សីហនុ, ប៉ែន-នុត និងសំរាប់ជនបរទេសនិងខ្មែរឯទៀតជាច្រើន ដែលចិញ្ចឹមសេចក្តីសង្ឃឹមទាំងស្រុងថា ប្រទេសកម្ពុជានឹងមាន«អនាគតភ្លឺស្វាង» ដោយសារពួកខ្មែរក្រហម (ដែលមានជូន

មុមម្នាក់នៅក្នុងនោះ ដែលអ្នកផងថ្លែងកោតសរសើរ)... គឺនៅសល់តែការ«ទទួលខ្លួនខុស»តែប៉ុណ្ណោះឯង, ដែលទោះជាយ៉ាងណា ក៏វាមិនអាចជួយសង្គ្រោះស្រុកខ្មែរឲ្យរស់ឡើងវិញបានដែរ, ដោយហេតុថា វិនាសកម្មនៃប្រទេសនេះ វាបានចារដោយព្រហ្មលិខិតរួចស្រេចទៅហើយ តាំងតែពីថ្ងៃ១៨មិនា១៩៧០មកម្ល៉េះ ។

ដើម្បីបញ្ចប់វគ្គនេះ ដែលសរសេរឡើងសំរាប់បំផុស«ព្រឹត្តិការណ៍ធំៗ»ទាក់ទងនឹងខែឧសភា១៩៧០, ខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញដល់មិត្តអ្នកអាន នូវនយោបាយផ្ទាល់ខ្លួន ដែលខ្ញុំព្រះករុណាខ្ញុំបានរៀបរៀងអំពីថ្ងៃ២០ឧសភា១៩៧០នៅទីក្រុងប៉េកាំង ។

២០ ឧសភា- គឺជាទិវាមួយដែលមានតម្លៃប្រវត្តិសាស្រ្តដ៏ពិតប្រាកដ ទោះសំរាប់ចលនាតស៊ូនៅប្រទេសកម្ពុជាក្តី ឬក៏សំរាប់ប្រទេសចិនប្រជាមានិតុក្តី ។

តាំងពីថ្ងៃម្សិលមិញម្ល៉េះ, នៅទីក្រុងប៉េកាំងក៏ដូចនៅទីកន្លែងដទៃទៀតទាំងអស់នៅប្រទេសចិន, ប្រជាពលរដ្ឋចិនទាំងមូលត្រូវបានគេបំផុសបំផុល «ចិត្តគំនិត» ឲ្យមានគោលជំហររឹងប៉ឹង ក្នុងប្រការជួយគាំទ្រប្រជាជាតិខ្មែរ និងឲ្យមានការស្អប់ខ្ពើមចំពោះចក្រពត្តិនិយមនៃសហរដ្ឋអាមេរិក»...

តាំងពីថ្ងៃទី១៦ឧសភាមកម្ល៉េះ (តាំងពីពេលរសៀលរហូតដល់រាត្រីធ្លាក់), ប្រជាពលរដ្ឋទាំងប្រុសទាំងស្រីរាប់រយពាន់នាក់ បានដើរចម្រុះខ្នលខ្នាញ់នៅតាមដងវិថីសំខាន់ៗនៃរដ្ឋធានី ។ ពួកគេបានស្រែកអំពាវនាវ អំពីការស្អប់របស់ពួកគេចំពោះ «ចក្រពត្តិនិយមអាមេរិកាំង» ហើយនិងការគាំទ្ររបស់ពួកគេចំពោះប្រជាពលរដ្ឋខ្មែរ ដែលទទួលរងគ្រោះដោយ«ការឈ្លានពាន» ។

នៅព្រឹកស្អែកឡើង ថ្ងៃទី២០ឧសភា, មនុស្សប្រមាណជាង១លាននាក់ បានមកហូរហៀរចូលពេញនៅទីកន្លែង «ទៀន-អាន់មេន» ។

មុននឹងចេញបង្ហាញខ្លួន មកទីកន្លែងវេទិកាធំដែលធ្វើពីថ្មចាក់បេតុង ហើយដែលមានកំពស់កំពរយ៉ាងសង្ហារ គ្របសង្កត់មកលើទីកន្លែងដ(ល្បីល្បាញនេះ លោកប្រធានម៉ៅ-សេទុង ដែលអមដោយ«មិត្តរួមអាវុធជិតស្និទ្ធជាងគេបំផុត», លោកសេនាប្រមុខលិន-ពាវ និងលោករដ្ឋមន្ត្រីទី១ជូ-អេនឡាយ, បានទទួលខ្ញុំព្រះករុណាខ្ញុំយ៉ាងរាក់ទាក់ជាទីបំផុតអស់ចំនួនកន្លះម៉ោង ។ សំដីសំដៅទាំងប៉ុន្មាន ដែលលោកបាននិយាយមកកាន់ខ្ញុំ... ជាការជាក់ច្បាស់ណាស់ គឺនិយាយឡើងសំរាប់លើកទឹកចិត្តខ្ញុំព្រះករុណាខ្ញុំ ដែលកំពុងតែធ្លាក់ស្រុតចុះយ៉ាងខ្លាំង ឲ្យមានជំនឿឡើងវិញ ទៅលើវាសនាអនាគតនៃមាតុប្រទេសរបស់ខ្ញុំព្រះករុណាខ្ញុំ ។

ទាក់ទងនឹងកាស៊ីណូនៅទីក្រុងភ្នំពេញ, លោកប្រធានម៉ៅបានថ្លែងមកកាន់ខ្ញុំព្រះករុណាខ្ញុំដូច្នេះថា ៖ «ប៉ុន្មានថ្ងៃចុងក្រោយនេះ ពួកលន់-នល់បានធ្វើការវាយ

ប្រហារសម្ដេចយ៉ាងខ្លាំងក្លា... ព្រមទាំងបន្ទះបង្អាប់សម្ដេចអំពីរឿងកាស៊ីណូ ។ តាមយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំ, ខ្ញុំយល់ឃើញថា សម្ដេចបានធ្វើចំណាត់ការត្រឹមត្រូវ ដោយយកប្រាក់ចំណូល មកទប់ទល់ការចំណាយនៅក្នុងកងទ័ព និងក្នុងកិច្ចការពារជាតិ ។ រឿងអស់ទាំងនេះ វាគ្រាន់បើជាងការពឹងផ្អែកទាំងស្រុងទៅលើជំនួយអាមេរិកាំងផងដែរ ដែលប្រកបដោយគ្រោះថ្នាក់ខ្លាំងណាស់ ហើយដែលមានលក្ខណៈចង្រៃឧត្បាតសំរាប់ឯករាជជាតិរបស់ព្រះអង្គ...» ។

(កកន ៖ សម្ដេចសីហនុជឿថា លោកប្រធានម៉ៅ-សេទុងនិយាយពីរឿងយកលុយកាស៊ីណូមកចិញ្ចឹមកងទ័ពនេះ ជាមធ្យោបាយសំរាប់តែលើកទឹកចិត្តទ្រង់តែប៉ុណ្ណោះ ។ ដូច្នេះសម្ដេចសីហនុខ្លួនឯងក៏យល់ថា ការយកប្រាក់ពីកាស៊ីណូមកចិញ្ចឹមកងទ័ពនេះ ពុំមែនជាចំណាត់ការត្រឹមត្រូវឡើយ...) ។

លោកប្រធានម៉ៅ បើទោះជាមានចំណាស់ទន់ជ្រាយខ្លាំងណាស់ទៅហើយ បើប្រៀបធៀបនឹងទ្រង់ទ្រាយរបស់លោកក្នុងទសវត្ស៦០ នៅតែមានគំនិតភ្លឺស្វាងនិងប្រាជ្ញាវាងវៃ ហើយនៅមានចំណូលចិត្តខាងនិយាយកំប្លែងស្លូត ។

ខ្ញុំព្រះករុណាខ្ញុំបានថ្លែងអំណរគុណចំពោះជំនួយដ៏សំបើមរបស់លោកប្រធានចំពោះចលនាតស៊ូដ៏ក្មេងខ្ចីរបស់យើង ។ លោកបានឆ្លើយមកខ្ញុំព្រះករុណាខ្ញុំវិញថា «ជាពិសេសសូមសម្ដេចកុំអរគុណពួកយើងធ្វើអ្វី ! គឺពួកយើងទេប្រទេសចិនដែលត្រូវអរគុណសម្ដេច, ពីព្រោះអាវុធរបស់យើង ប្រាក់កាសរបស់យើង ដែលផ្ដល់ឲ្យប្រជាពលរដ្ឋតស៊ូនៅប្រទេសកម្ពុជា មិនមានតម្លៃអ្វីសំខាន់ទាល់តែសោះ បើប្រៀបធៀបនឹងពលិកម្មដ៏មហាអស្ចារ្យនៃប្រជាពលរដ្ឋនេះ ដែលស្ថិតនៅជួរមុខនៃខ្សែប្រយុទ្ធតទល់នឹងចក្រពត្តិអាមេរិកាំង ។ គឺពលរដ្ឋខ្មែរ, ពលរដ្ឋវៀតណាម, ពលរដ្ឋលាវ ដែលបង្ហូរឈាមខ្លួនឯងក្នុងប្រយុទ្ធនេះ... ពុំមែនយើងដែលជាជនជាតិចិននោះទេ ។ ហើយគឺពួកយើងនេះឯង ដែលបានទទួលយកផលចំណេញ ពីជោគជ័យរបស់លោកអ្នក», នេះបានហៅថា ការនិយាយគ្នាដោយស្មោះត្រង់និងសុចរិត !

ចំណែកលោកសេនាប្រមុខលិន-ពាវវិញ, បុរសម្នាក់មាឌតូចល្អិត ស្គមហើយស្ងួតសោះកគ្រោះ, កាលពីព្រឹកថ្ងៃនោះ, ខ្ញុំព្រះករុណាខ្ញុំបានក្រឡេកមើលទៅឃើញគាត់ទំនងដូចជាជនស្រទឹងម្នាក់, ហើយដែលម្ដងម្កាល បានបង្អាក់លោកប្រធានម៉ៅ ដើម្បីស្រែកឆ្កាដៃឆ្កាជើងជេរសហរដ្ឋអាមេរិក ព្រមទាំងបានផ្ដល់ដល់ខ្ញុំព្រះករុណាខ្ញុំ នូវសេចក្ដីធានាអះអាងទាំងស្រុង ដែលគ្មានរង្គោះរង្គើ នៃការគាំទ្ររបស់ប្រទេសចិន និងក្រុមយោធារបស់លោក «រហូតទៅដល់ជោគជ័យជាទីបញ្ចប់» ។ លោកបានបញ្ជាក់ប្រាប់ខ្ញុំព្រះករុណាខ្ញុំថា លោកនឹងមិនយកថ្លៃថ្នូរអ្វីឡើយ ពីជំនួយច្រើនមុខច្រើនយ៉ាង ដែលផ្ដល់ឲ្យហ្វ៊ុង-គ្រុងរបស់ពួកយើង ហើយដែលចលនា

និងរដ្ឋាភិបាលនេះ មិនត្រូវញញើតញញើមសោះឡើយ នឹងស្នើសុំចំពោះប្រទេសចិន នូវអ្វីៗទាំងអស់ ដែលចលនាតស៊ូរបស់យើងមានសេចក្តីត្រូវការ ។

លោករដ្ឋមន្រ្តីទី១ជូ-អេនឡាយ ដែលជាមនុស្សមានបញ្ញាល្អិតល្អន់ ស្ងាត់ស្ងៀម ហើយមានសេចក្តីគោរពយ៉ាងជ្រាលជ្រៅចំពោះលោកប្រធានម៉ៅ ដែលបើកមាត់និយាយស្ទើរតែសំរាប់តែឆ្លើយចំពោះចំណុចខ្លះៗ ដែលលោកប្រធានបានចោទសួរ និងដើម្បីថ្លែងសរសើរកិច្ចការកសាងជាតិជាទូទៅនៃខ្ញុំព្រះករុណាខ្ញុំនៅកម្ពុជា ចន្លោះឆ្នាំ១៩៥៣និង១៩៦៩ ។

លោកជូ-អេនឡាយបានថ្លែងទៅកាន់លោកប្រធានម៉ៅថា គឺជាការមួយគួរឲ្យសោកស្តាយពន់ពេក ដែលកិច្ចការកសាងជាតិទាំងអស់នេះ បានត្រូវបញ្ចប់ដោយកំហុក ដោយសារតែពួកក្រុមរដ្ឋប្រហារនៅភ្នំពេញ, ដោយលោកបានបន្ថែមថា «ដោយបានយល់ស្គាល់ប្រទេសជាច្រើននៅក្នុងតតិយលោក» លោកមានលទ្ធភាព «ធ្វើសេចក្តីបញ្ជាក់ថា នៅក្រោមការដឹកនាំរបស់សម្តេចសីហនុ ប្រទេសកម្ពុជាបានបោះជំហានជឿនលឿនទៅមុខក្នុងកិច្ចកសាងជាតិ ជាងប្រទេសដទៃទៀតភាគច្រើន ដែលកំពុងធ្វើដំណើរឆ្ពោះទៅរកការរីកចំរើន» ។

មិត្តជូ-អេនឡាយរបស់ខ្ញុំព្រះករុណាខ្ញុំ ក៏បានឆ្លៀតឱកាសពេលនោះ... ហើយគាត់តែងតែឆ្លៀតឱកាសជានិច្ច រហូតដល់សេចក្តីស្លាប់របស់គាត់ ដើម្បីធ្វើមេធាវីការពារឧត្តមគតិខ្ញុំព្រះករុណាខ្ញុំដោយសេចក្តីស្មោះស្ម័គ្រ នៅចំពោះមុខប្រជាពលរដ្ឋរបស់គាត់ក្តី នៅចំពោះមុខពួកជនបរទេសក្តី (ជាពិសេសនៅចំពោះមុខពួកអនាគតមិត្តភក្តិអាមេរិកាំងរបស់គាត់)... ឬនៅចំពោះមុខពួកមេដឹកនាំខ្មែរក្រហមក្តី...។

ពីថ្ងៃនេះតទៅ ខ្ញុំព្រះករុណាខ្ញុំមិនអាចបំភ្លេចបានឡើយ នូវអ្វីៗដែលគាត់បានធ្វើចំពោះខ្ញុំព្រះករុណាខ្ញុំ ។

បើយើងវិលត្រឡប់មកកិច្ចប្រជុំមេទីងដ៏មហាសំបើម នៅថ្ងៃទី២០ ឧសភា ១៩៧០, នៅទៀន-អាន់មេន, ការបង្ហាញខ្លួនរបស់លោកប្រធានម៉ៅ ជាមួយនឹងខ្ញុំព្រះករុណាខ្ញុំនៅខាងស្តាំ ហើយនិងលោកលិន-ពាវនៅខាងឆ្វេង ដោយមានបន្ទាប់មកទៀត នូវវត្តមានរបស់លោកជូ-អេនឡាយ បានធ្វើឲ្យពួកប្រជាពលករចិនប្រមាណជាង១លាននាក់ ទះដៃខ្ទរខ្ទារដូចសម្លេងរន្ទះ ព្រមទាំងបានបញ្ចេញសំរែកហ៊ោកញ្ជៀវអឺងកងដ៏យូរលង់ ។

គេឃើញវត្តមានក្រុមភ្នាក់ងារទូត ហើយនិងពួកអ្នកតំណាងសារពត៌មានបរទេស (ពួកក្រោយនេះមានចំនួនតិចតួចណាស់) នៅទីកន្លែងវេទិកាធំនោះ ។

បន្ទាប់ពីសេចក្តីថ្លែងការណ៍របស់លោកប្រធានម៉ៅ, ខ្ញុំព្រះករុណាខ្ញុំក៏បានទទួលកិត្តិយសដ៏ពិសេសពិសាល គ្មានពីរសំរាប់ជនបរទេស, គឺត្រូវបានអនុញ្ញាតឲ្យថ្លែ

ងសង្កថាពីលើមហាវេទិកានោះផងដែរ ។

ដើម្បីបញ្ចប់វគ្គនេះ ខ្ញុំព្រះករុណាខ្ញុំសូមសេចក្ដីអនុញ្ញាតធ្វើការផ្សាយទាំងស្រុង នូវអត្ថបទដ៏មហាសំខាន់ចំពោះមុខប្រវត្តិសាស្ត្រ នៃសេចក្ដីថ្លែងការណ៍របស់លោកប្រធានម៉ៅ-សេទុង នៅថ្ងៃទី២០ឧសភាឆ្នាំ១៩៧០ (ជាអត្ថបទដ៏មហាសំខាន់, ខ្ញុំព្រះករុណាខ្ញុំសូមបញ្ជាក់ ពីព្រោះថា ផ្ទុយពីអំនួតក្ដុងក្ដាំងរបស់លោកនិចសុន កាលពីថ្ងៃទី១ឧសភា១៩៧០, សេចក្ដីប្រកាសរបស់លោកម៉ៅ-សេទុងនៃថ្ងៃទី២០ឧសភា១៩៧០ គឺជាចំណុចផ្ដើមដំបូង ដែលឈានទៅរកជោគជ័យដ៏មហាអស្ចារ្យនៃសាធារណរដ្ឋប្រជាមានិតចិន ទៅលើសហរដ្ឋអាមេរិកនិងទៅលើសហភាពសូវៀត, នៅប្រទេសកម្ពុជា, ដោយការកាន់កាប់ក្ដោបក្ដាប់អំណាចពីសំណាក់ពួកខ្មែរក្រហមនៅក្នុងប្រទេសនៃខ្ញុំព្រះករុណាខ្ញុំ នៅថ្ងៃទី១៧មេសា១៩៧៥) ៖

ពលរដ្ឋទាំងឡាយនៃពិភពលោក, ចូររួបរួមគ្នាឡើង ដើម្បីកំទេចពួកឈ្លានពានអាមេរិកាំង និងខ្ញុំកញ្ជះរបស់វា !

ម៉ៅ-សេទុង

(២០ ឧសភា ១៩៧០)

នៅក្នុងពេលបច្ចុប្បន្ននេះ, វាមានសន្ទុះកាន់តែខ្ពស់ឡើងក្នុងកំពស់កំពរនៃពិភពលោកតែម្ដង បៃការប្រយុទ្ធតស៊ូប្រឆាំងនឹងចក្រពត្តិនិយមអាមេរិកាំងនិងពួកក្រុមបរិវារ ដែលចេះតែបង្កើតសង្គ្រាមឈ្លានពានគ្មានឈប់ឈរ, ម្ល៉ោះហើយក្រុមប្រជាពលករក៏តែងតែប្រើវិធីនៃសង្គ្រាមបដិវត្តន៍ ដើម្បីយកជ័យជំនះទៅលើពួកឈ្លានពាន ។ គ្រោះថ្នាក់នៃការផ្ទុះសង្គ្រាមពិភពលោកថ្មីមួយទៀត នៅតែមានជានិច្ច ហើយពលរដ្ឋនៅពិភពលោកទាំងមូល ត្រូវតែរៀបចំខ្លួនឲ្យហើយ ។ ក៏ប៉ុន្តែនៅក្នុងពេលសព្វថ្ងៃនេះ, នៅក្នុងពិភពលោកទាំងមូល ទំនោរដ៏សំខាន់ជាងគេបំផុត, គឺបដិវត្តន៍ ។

ពួកឈ្លានពានអាមេរិកាំង ដោយមិនអាចដណ្ដើមយកជោគជ័យបាន នៅក្នុងសង្គ្រាមវៀតណាមនិងលាវ ក៏បានរៀបចំបង្កើតឲ្យមានរដ្ឋប្រហារប្រតិកិរិយានៃពួកក្រុមបនលន់នល់-សិរិមតៈ, ដោយបានបញ្ជូនកងទ័ពខ្លួន ដោយឥតអៀនខ្មាស់ទៅប្រទេសកម្ពុជា ហើយក៏បានចាប់ផ្ដើមទម្លាក់គ្រាប់បែកឡើងវិញទៅលើវៀតណាមខាងជើង... ដែលជាហេតុបណ្ដាលឲ្យមានការតស៊ូដោយសេចក្ដីក្ដៅក្រហាយនៃពលរដ្ឋទាំងបីនៅឥណ្ឌូចិន ។ ខ្ញុំសូមគាំទ្រយ៉ាងកក់ក្ដៅ នូវគោលគំនិតយស៊ូរបសម្ដេចនរោត្តម-សីហនុ, ប្រមុខរដ្ឋនៃប្រទេសកម្ពុជា, ប្រឆាំងនឹងចក្រពត្តិនិយមនិងពួកខ្ញុំកញ្ជះរបស់វា ។ ខ្ញុំសូមគាំទ្រយ៉ាងកក់ក្ដៅនូវសេចក្ដីថ្លែងប្រកាសរួមនៃប្រជាពលរដ្ឋឥណ្ឌូចិន ។ ខ្ញុំសូមគាំទ្រការបង្កើតរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលស្ថិតនៅ

ក្រោមការដឹកនាំនៃរណសិរ្សរួបរួមជាតិកម្ពុជា ។ ដោយរឹតចំណងឯកភាពនេះឲ្យរឹងប៉ឹង, ដោយជួយឧនត្ថម្ភគ្នាទៅវិញទៅមក ហើយដោយបន្តសង្គ្រាមតស៊ូប្រជាប្រិយមួយឲ្យបានយូរអង្វែង  ប្រជាពលរដ្ឋឥណ្ឌូចិនទាំងបីនឹងអាចគ្របសង្កត់ទៅលើសេចក្តីទុកលំបាកគ្រប់យ៉ាងព្រមទាំងអាចកញ្ឆក់តណ្តើមយកជោជ័យបានទាំងស្រុង ។

ចក្រពត្តិនិយមអាមេរិកាំង  នៅពេលដែលពួកគេធ្វើការពិឃាតរង្គាលនៅឯបរទេស, ពួកគេក៏បានសម្លាប់ពួកស្បែកសនិងពួកស្បែកខ្មៅ នៅក្នុងប្រទេសរបស់ខ្លួនឯងផងដែរ ។ អំពើហិង្សារបស់និចសុន ក៏បានព្រួសឲ្យចេញអណ្តាតភ្លើងសន្ធោសន្ធៅក្តៅគគុកនៃចលនាបដិវត្តន៍ប្រជាពលករនៅសហរដ្ឋអាមេរិក ។ ដោយមានវីរភាពក្នុងការតស៊ូប្រយុទ្ធ  ប្រជាពលរដ្ឋអាមេរិកាំងនឹងក្លាយទៅជាអ្នកឈ្នះ  រីឯការគ្របសង្កត់នៃលទ្ធិហ្វាស៊ីស្សនៅសហរដ្ឋអាមេរិក  ក៏នឹងបានទទួលបរាជ័យយ៉ាងពិតប្រាកដ ។ នេះជាជំនឿដ៏មុតមាំរបស់ខ្ញុំ ។

រដ្ឋការនិចសុនកំពុងតែត្រូវវាយប្រហារដោយសេចក្តីលំបាកច្រើនមុខច្រើនយ៉ាង ទោះនៅក្នុងផ្ទៃក្នុងក្តី ទោះមកពីខាងក្រៅក្តី ៖ រដ្ឋការនេះកំពុងមានអនាធិបតេយ្យវក់វី ហើយមិនសូវមានចំណងមិត្តភក្តិជាមួយនិងពិភពខាងក្រៅនោះទេ ។ ចលនាប្រជាពលករដែលធ្វើការប្រឆាំងនឹងការឈ្លានពានអាមេរិកាំងនៅប្រទេសកម្ពុជា កំពុងតែរាលដាលពាសពេញពិភពលោកទាំងមូល ។ មិនបានដប់ថ្ងៃផង បន្ទាប់ពីចេញរូបរាងឡើង, រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានត្រូវប្រទេសដទៃទៀតចំនួនក្បែរម្ភៃទៅហើយ ធ្វើការទទួលស្គាល់ ។ សង្គ្រាមតស៊ូនៃពលរដ្ឋវៀតណាម លាវ និងកម្ពុជា  តទល់នឹងការឈ្លានពានអាមេរិកាំង  ហើយនិងដើម្បីជាអាយុជីវិតរបស់ជាតិ កំពុងតែស្គាល់សភាពការណ៍ប្រសើរឡើងជារៀងរាល់ថ្ងៃ ។ ការតស៊ូប្រយុទ្ធនៃយោធាបដិវត្តន៍នៃពលរដ្ឋនៅអាស៊ីអាគ្នេយ៍, ការប្រយុទ្ធនៃពលរដ្ឋនៅកូរ៉េ, ជប៉ុនហើយនិងប្រទេសអាស៊ីដទៃទៀត  តទល់នឹងការរស់នៅឡើងវិញនៃយោធានិយមអាមេរិកាំង ដែលប្រព្រឹត្តឡើងដោយក្រុមប្រតិកិរិយាអាមេរិកាំង, ជប៉ុន, ការតស៊ូនៃពលរដ្ឋប៉ាឡេស្ទីន ហើយនិងប្រជាពលរដ្ឋអារ៉ាប់ដទៃទៀត តទល់នឹងពួកឈ្លានពានអាមេរិកាំង–អ៊ីស្រាអែល, ការតស៊ូប្រយុទ្ធនៃពលរដ្ឋអាស៊ីម អាហ្វ្រិក និងអាមេរិកឡាទីន (ខាងត្បូង) ដើម្បីធ្វើការរំដោះប្រជាជាតិ  ព្រមទាំងការតស៊ូបដិវត្តន៍នៃពលរដ្ឋនៅអាមេរិកខាងជើង  នៅអឺរ៉ុប  និងអុសសេអានី (ប្រជាជននៃកោះសមុទ្រ ៖ អូស្ត្រាលី, នូសេឡិន, ហាវ៉ៃ ។ល។ កំពុងតែមានការរីកធំឡើងយ៉ាងខ្លាំងក្លា ។ ប្រជាពលរដ្ឋចិនគាំទ្រយ៉ាងរឹងប៉ឹង  ពលរដ្ឋឥណ្ឌូចិនទាំងបីនិងពលរដ្ឋដទៃទៀតនៅក្នុងពិភពលោកទាំងមូល  នៅក្នុងការប្រយុទ្ធតស៊ូបដិវត្តន៍រៀងៗខ្លួន  តទល់នឹងចក្រពត្តិនិយមអាមេរិកាំង ហើយពួកខ្ញុំកញ្ជះរបស់វា ។

ចក្រពត្តិនិយមអាមេរិកាំងមានលក្ខណៈដូចជាយក្ស, ក៏ប៉ុន្តែតាមការពិត វាគ្រាន់តែជាខ្លាក្រដាស់តែប៉ុណ្ណោះ, ហើយវាកំពុងតែរើបំរះប្រទ្រុះប្រទ្រះយ៉ាងគួរឲ្យអស់សង្ឃឹម ។ គិតឲ្យបានវែងឆ្ងាយទៅ តើមាននរណាខ្លាចនរណាទៀតក្នុងពេលសព្វថ្ងៃនេះ ? គឺមិនមែនពលរដ្ឋវៀតណាម, លាវ, កម្ពុជា, ប៉ាឡេស្ទីន, ពលរដ្ឋនៃប្រទេសអារ៉ាប់ទាំងឡាយ និងពលរដ្ឋនៅទីកន្លែងផ្សេងៗទៀតក្នុងពិភពលោកនោះទេ ដែលត្រូវភ័យខ្លាចនឹងចក្រពត្តិអាមេរិកាំង, គឺចក្រពត្តិអាមេរិកាំងទៅវិញទេ ដែលត្រូវភ័យខ្លាចនឹងពលរដ្ឋនៃពិភពលោក ។ ឲ្យតែមានការរំជើបរំជួលអ្វីតែបន្តិចបន្តួច, ចក្រពត្តិនេះតែងតែមានការភ័យញ៉ូវញ៉ាក់ស្លន់ស្លោ ។ មានព្រឹត្តិការណ៍ច្រើនណាស់ដែលជាភស្តុតាងបង្ហាញថា គោលជំហរត្រឹមត្រូវតែងត្រូវបានទទួលសេចក្តីគាំទ្រទូលំទូលាយ, ចំណែកឯគោលជំហរអយុត្តិធម៌វិញ ពុំសូវបានទទួលការគាំទ្រសោះឡើយ ។ ប្រទេសទន់ខ្សោយមួយអាចយកជ័យជំនះ ទៅលើប្រទេសខ្លាំងមួយបាន ហើយប្រទេសមួយតូច អាចមានលទ្ធភាពឈ្នះប្រទេសមួយធំ ។ ពលរដ្ឋនៃប្រទេសមួយដ៏តូច នឹងអាចយកជ័យជំនះយ៉ាងពិតប្រាកដ ទៅលើការឈ្លានពាននៃប្រទេសមួយដ៏ធំ, ប្រសិនបើពួកគេហ៊ានងើបឡើងប្រយុទ្ធតស៊ូ កាន់អាវុធនៅដៃ ហើយទទួលកាន់កាប់វាសនានៃប្រទេសរបស់ខ្លួនឯង ។ នេះហើយគឺជាច្បាប់នៃប្រវត្តិសាស្ត្រ ។

ពលរដ្ឋពិភពលោក, ចូររួបរួមគ្នាឡើង ដើម្បីកំចាត់ពួកឈ្លានពានអាមេរិកាំងនិងខ្ញុំកញ្ជះរបស់វា !

❑